# អច្ឆរិយវត្ថុទាំង៧នៃយុគបុរាណ

## នាំអ្នកទៅជួបជាមួយនឹងអរិយធម៌ដ៏រុងរឿងនៃលោកបុរាណ



សុមនោ

ATB Center

eLibrary of Cambodia 2016

# អច្ឆរិយវត្ថុទាំង៧នៃយុគបុរាណ



សុមនោ

...សៀវភៅគុណភាព...ខ្លឹមសារពិស្តារ...រូបភាពស្រស់ស្រាយ...បង្កើនចំណេះដឹង...

ផ្សាយចេញពីបណ្ណាគារ អង្គរធំ

រក្សាសិទ្ធិ

2006

អច្ឆរិយវត្ថុទាំង៧ ( យុគបុរាណ )

ដោយ **សុមនោ**

បោះពុម្ពលើកទីមួយ : មីនា ២០០៦

ផ្ទៀងផ្ទាត់អក្ខរាវិរុទ្ធដោយ : កញ្ញា ជា កេសរ

សូមថ្លែងអំណរគុណជាពិសេសចំពោះ : កញ្ញា ជា វីណែត

ផ្សាយចេញពី : បណ្ណាគារ " **អង្គរធំ** "

បោះពុម្ពដោយ : រោងពុម្ព **ម៉េងហាង**

# អារម្ភកថា

បើទុកណាជាមានមនុស្សភាគច្រើន នៅលើពិភពលោកនេះបានដឹងថា អច្ឆរិយវត្ថុនៅក្នុងលោកមានចំនួន៧ក៏ដោយ ប៉ុន្តែមានមនុស្សតិចណាស់ដែលបានដឹងអំពីឈ្មោះ និងរឿងរ៉ាវមួយចំនួន ដែលទាក់ទងទៅនឹងវត្ថុដ៏អស្ចារ្យទាំង៧នេះ។ ឯកសារមុនគេបង្អស់ស្តីអំពីវត្ថុដ៏អស្ចារ្យទាំងនេះ ត្រូវបានសរសេរឡើងនៅក្នុងសតវត្សន៍ ទី៥មុន គ.ស ដោយប្រវត្តិវិទូសញ្ជាតិក្រិចដែលមានឈ្មោះថា **ហេរ៉ូ ដូទូស** (Hero- dotus) ។ ៣ សតវត្សន៍បន្ទាប់( ស.វទី២មុនគ.ស) ប្រវិត្តវិទូក្រិចម្នាក់ផ្សេងទៀត នោះគឺលោក**អង់ទីប៉ាទើរ** (Antipater) បានចងក្រងនូវបញ្ជីរាយនាមអច្ឆរិយវត្ថុទាំង៧ ឡើងជាលើកដំបូងបំផុត។ មិត្តអ្នកអានប្រាកដជាឆ្ងល់ថា ហេតុអ្វីទើបបានជាលោកអង់ទីប៉ាទើរ ចងក្រងនូវអច្ឆរិយវត្ថុត្រឹមតែ៧យ៉ាងដូច្នេះ ឬមួយថាវាមានត្រឹមតែ៧ទេ? ចម្លើយគឺថាវាមិនមែនមានត្រឹមតែ៧ប៉ុណ្ណោះទេ ប៉ុន្តែការដែលគាត់ចងក្រងឡើងមកត្រឹម៧យ៉ាងដូច្នេះ គឺដោយយោងទៅតាមជំនឿរបស់ជនជាតិក្រិចបុរាណ ដែលយល់ថាលេខ៧គឺជាលេខដ៏ល្អ( មានហុងស៊ុយ...) ទាំងមានប្រវត្តិទាក់ទងនឹងរឿងរ៉ាវជាច្រើន ក្នុងទេវកថាក្រិចថែមទៀតផង។ រហូតមកដល់យុគសម័យកណ្តាល( គ.ស៤០០ដល់ ១៥០០) ទើបបញ្ជីរាយនាមខាងលើត្រូវបានគេសរសេរយ៉ាងពិស្តារបន្ថែមទៀត ដែលនិយាយស្តីអំពីអនុស្សាវរីយស្ថានដ៏ល្អឥតខ្ចោះ និងគួរឱ្យចង់ទស្សនាបំផុតចំនួន៧ នៅក្នុងយុគសម័យបុរាណនោះគឺ

១. មហាពីរ៉ាមីត នា ហ្គីហ្សា ( ប្រទេសអេហ្ស៊ីប)

២. ឧទ្យានបណ្តែតបាប៊ីឡូន ( ប្រទេសអ៊ីរ៉ាក់)

៣. មហាទេវរូបហ្សេអ៊ូស ( ប្រទេសក្រិច)

៤.	មហាប្រាសាទដាយអាណា ( ប្រទេសទួរគី)

៥.	មហាចេតិយ ម៉ូសូលៀម ( ប្រទេសទួរគី)

៦.	សើន ហ្វារ៉ូ ( ប្រទេសអេហ្ស៊ីប)

៧.	មហាទេវរូប ខូឡូស៊ុស ( ប្រទេសក្រិច)

មកដល់ត្រង់ចំណុចនេះ អាចមានមិត្តអ្នកអានខ្លះមានចម្ងល់ថា ចុះហេតុអ្វីទើបមិនឃើញមាននិយាយអំពី "**ប្រាសាទអង្គរវត្ត**"ដ៏ល្បីល្បាញរបស់ខ្មែរយើង នៅក្នុងបញ្ជីរាយនាមនៃអច្ឆរិយវត្ថុទាំង៧ខាងលើនេះផង (ក្រែងថាប្រាសាទអង្គរវត្តរបស់ខ្មែរជាអច្ឆរិយវត្ថុមួយក្នុងចំណោមអច្ឆរិយវត្ថុទាំង៧នោះអី?) ។ ចំពោះចម្ងល់ខាងលើនេះ ខ្ញុំបាទដែលជាអ្នករៀបរៀង សូមឆ្លើយបញ្ជាក់នៅក្នុងទីនេះតែម្តងថា រាល់បណ្តាស្ថាបនកម្មនៅក្នុងលោក ដែលគេចាត់ទុកថាជាវត្ថុដ៏អស្ចារ្យ ឬជាសំណង់ដែលគេសង់បានដោយលំបាកនោះ អ្នកបុរាណវិទ្យាទាំងឡាយ បានធ្វើការបែងចែកចេញជា៣យុគសម័យដូចតទៅ

១.	អច្ឆរិយវត្ថុទាំង៧នៃយុគបុរាណ

២.	អច្ឆរិយវត្ថុទាំង៧នៃយុគកណ្តាល

៣.	អច្ឆរិយវត្ថុទាំង៧នៃបច្ឆិមយុគ( យុគចុងក្រោយ)

សម្រាប់ប្រាសាទអង្គរវត្តដ៏ល្បីល្បាញរបស់ខ្មែរយើង គឺត្រូវបានគេរាប់បញ្ចូលទៅក្នុងអច្ឆរិយវត្ថុទាំង៧ នៃយុគសម័យកណ្តាល (សូមរង់ចាំអានសៀវភៅស្តីអំពី "អច្ឆរិយវត្ថុទាំង៧នៃយុគកណ្តាល" ដែលនឹងចេញផ្សាយនាពេលឆាប់ៗនេះ) ដូច្នេះទើបមិនឃើញមានការរំលឹកដល់ នៅក្នុងអច្ឆរិយវត្ថុទាំង៧នៃយុគបុរាណ។

ចំពោះគោលបំណងនៅក្នុងការសាងសង់ នូវសំណង់ដ៏អស្ចារ្យទាំង៧នេះទៀតសោត គឺមួយចំនួនត្រូវបានគេសាងសង់ឡើង សម្រាប់ជាការឧទ្ទិសដល់អាទិទេព ក្នុងខណៈដែលមួយចំនួនទៀត គឺសាងសង់ឡើងសម្រាប់ទុកដាក់ដូចជាផ្នូរ របស់មហាក្សត្រ

ក្រោយការចូលទីវង្គត់ ឬសម្រាប់បង្ហាញពីអំណាច ជាដើម ។

បច្ចុប្បន្នតាមរយៈការសិក្សាស្រាវជ្រាវ របស់អ្នកបុរាណវិទ្យាបានបង្ហើបប្រាប់ឱ្យយើងដឹងអំពី រឿងរ៉ាវអាថ៌កំបាំងមួយចំនួនទាក់ទងទៅនឹងវត្ថុដ៏អស្ចារ្យទាំងនោះ ក៏ដូចជាវប្បធម៌ និងអរិយធម៌នៃសម័យអតីតកាលដ៏រុងរឿង ដែលបានកប់បាត់ស្ងាត់ឈឹង អស់រយៈពេលរាប់រយឆ្នាំកន្លងមកហើយ ។

សូមបញ្ជាក់ថាអច្ឆរិយវត្ថុទាំង៧នៃយុគបុរាណ បច្ចុប្បន្នបានវិនាសបាត់បង់អស់ចំនួន៦ហើយដោយគ្រោះធម្មជាតិ និងដោយស្នាដៃរបស់មនុស្ស រីឯអច្ឆរិយវត្ថុមួយដែលនៅសល់នោះ គឺមហាពីរ៉ាមីត ដែលសព្វថ្ងៃស្ថិតនៅប្រទេសអេហ្ស៊ីប ។
សម្រាប់យោបល់ណែនាំ ឬចម្ងល់ផ្សេងៗ សូមទូរស័ព្ទមកលេខ ០១៦ ៤៥ ៤៥ ៤៥ ឬផ្ញើមកតាមរយៈអាស័យដ្ឋាន somano_khmer@yahoo.com ។

# មាតិការឿង

**និទ្ទេសបទ** **ទំព័រ**


- ផែនទីបង្ហាញពីទីតាំងនៃអច្ឆរិយវត្ថុទាំង៧ ...................... ៦
- អច្ឆរិយវត្ថុទី១ ( មហាពីរ៉ាមីត នាហ្គីហ្សា) ...................... ១៥
- អច្ឆរិយវត្ថុទី២ ( ឧទ្យានបណ្តែត បាប៊ីឡូន) ...................... ២៨
- អច្ឆរិយវត្ថុទី៣ ( មហាទេវរូប ហ្សេអ៊ូស) ...................... ៤១
- អច្ឆរិយវត្ថុទី៤ ( មហាប្រាសាទ ដាយអាណា) ...................... ៥៣
- អច្ឆរិយវត្ថុទី៥ ( មហាចេតិយ ម៉ូសូលៀម) ...................... ៦៧
- អច្ឆរិយវត្ថុទី៦ ( សើនហ្វារ៉ូ នាអាឡិចសាន់ដ្រា) ...................... ៨០
- អច្ឆរិយវត្ថុទី៧ ( មហាទេវរូប ខូឡូស៊ុស) ...................... ៩២

# ផែនទីបង្ហាញទីតាំងអច្ឆរិយវត្ថុទាំង៧នៃយុគបុរាណ




១. មហាពីរ៉ាមីត នា ហ្គីហ្សា ( ប្រទេសអេហ្ស៊ីប)

២. ឧទ្យានបណ្តែតបាប៊ីឡូន ( ប្រទេសអ៊ីរ៉ាក់)

៣. មហាទេវរូបហ្សេអ៊ូស ( ប្រទេសក្រិច)

៤. មហាប្រាសាទដាយអាណា ( ប្រទេសទួរគី)

៥. មហាចេតិយ ម៉ូសូលៀម ( ប្រទេសទួរគី)

៦. សើន ហ្វារ៉ូ ( ប្រទេសអេហ្ស៊ីប)

៧. មហាទេវរូប ខូឡូស៊ុស ( ប្រទេសក្រិច)


មហាពីរ៉ាមីត ណាហ្គីហ្សា


ឧទ្យានបណ្តែត បាប៊ីឡូន



មហាទេវរូបហ្សេអ៊ូស


មហាប្រាសាទដាយអាណា


មហាចេតិយម៉ូសូលៀម


សើនហ្វារ៉ូ នាអាឡិចសាន់ឌ្រា


មហាទេវរូប ខូឡូស៊ុស




- ឈ្មោះ : ពីរ៉ាមីត ឃូហ្វ៊ូ
- ទីតាំង : នា ហ្គីហ្សា ប្រទេស អេហ្ស៊ីប
- ឆ្នាំកសាង : ២៥៨៩-២៥៦៦មុនគ.ស
- កសាងដោយ : ព្រះចៅចក្រពត្តិ ហ្វារ៉ូ ឃូហ្វ៊ូ
- វត្ថុបំណង : ទុកជាទីតម្កល់ព្រះសពរបស់ព្រះអង្គ

ជាបុរាណស្ថានមួយ ដែលបង្ហាញអំពីអតីតកាលដ៏រុងរឿង នៃអាណាចក្រអេហ្ស៊ីបបុរាណ ពីរ៉ាមីតត្រូវបានគេចាត់បញ្ចូលជាអច្ឆរិយវត្ថុមួយ ក្នុងចំណោមអច្ឆរិយវត្ថុទាំង៧របស់ពិភពលោក ហើយក៏ជាអច្ឆរិយវត្ថុតែមួយគត់ នៃយុគបុរាណដែលនៅស្ថិតស្ថេរគង់វង្សរហូតមកដល់បច្ចុប្បន្ន (អច្ឆរិយវត្ថុ៦ផ្សេងទៀតត្រូវបានវិនាសបាត់បង់អស់ទៅហើយ)។

វាគឺជាអច្ឆរិយវត្ថុមួយនៅក្នុងលោក ដែលគួរឱ្យកោតស្ញប់ស្ញែងហួសនឹងបរិយាយបាន ហើយមិនចាំបាច់ទាមទារឱ្យមានការអធិប្បាយ ពីសំណាក់អ្នកបុរាណវិទ្យា ឬពីកវីនិពន្ធណាមួយឡើយ។ អ្នកនឹងបាត់ឆ្ងល់អំពីថាតើហេតុអ្វីពីរ៉ាមីតត្រូវបានគេចាត់បញ្ចូលជាអច្ឆរិយវត្ថុមួយ ក្នុងចំណោមអច្ឆរិយវត្ថុទាំង៧នៅក្នុងលោក នៅពេលដែលអ្នកបានទៅឃើញផ្ទាល់នឹងភ្នែករបស់អ្នក នូវលក្ខណៈទ្រង់ទ្រាយទំហំ និងពីភាពអស្ចារ្យរបស់វា។

មិនខុសពីប្រាសាទអង្គរវត្តនៅប្រទេសកម្ពុជារបស់យើង ឬពីថាច់ម៉ាហាលនៅឥណ្ឌាប៉ុន្មានឡើយ ពីរ៉ាមីតត្រូវបានកសាងឡើង ដោយព្រះមហាក្សត្របុរាណរបស់អេហ្ស៊ីប ក្នុងសម័យដែលអរិយធម៌នៅតាមដងទន្លេនីល មានការរីកចម្រើនដល់កម្រិតកំពូល សម្រាប់ទុកជាទីតម្កល់ព្រះសពរបស់មហាក្សត្រទាំងនោះ ក្រោយការចូលទីវង្គត់របស់ព្រះអង្គ ហើយដែលត្រូវបានគេគោរពលើកតម្កើង ស្មើនឹងព្រះជាម្ចាស់។

ពីរ៉ាមីតជាច្រើនត្រូវបានគេអះអាងថា បានកសាងឡើងក្នុងអំឡុងរាជវង្សទី៤ (ពីឆ្នាំ២៦៨០ដល់២៥៤៤មុន គ.ស)។ ពីរ៉ាមីតដំបូងនិងធំជាងគេបំផុត ហើយ

ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញក្នុង ចំណោមស្ថាបត្យកម្មនៃពីរ៉ាមីតទាំងឡាយរបស់អេហ្ស៊ីប ត្រូវបានកសាងឡើងនៅក្នុងរជ្ជសម័យ របស់ព្រះចៅចក្រពត្តិអេហ្ស៊ីប ព្រះនាមថាហ្វារ៉ូ ឃូហ្វ៊ូ (PharaohKhufu) ក្នុងកំឡុងឆ្នាំ២៥៨៩ ដល់ ២៥៦៦ មុនគ.ស សម្រាប់ទុកជាផ្នូរ ( ទីដែលព្រះអង្គនឹងចាប់ផ្ដើមជីវិតថ្មី ដ៏អាថ៌កំបាំងរបស់ព្រះអង្គក្រោយការចូលទីវង្គត់) បញ្ចុះព្រះសពរបស់ព្រះចៅចក្រពត្តិអង្គនេះ ។




**មហាពីរ៉ាមីតឃូហ្វ៊ូមើលពីចម្ងាយ( រូបដែលឃើញនៅខាងមុខនេះគឺជារូបចម្លាក់នរសិង្ហខ្នាតយក្ស)**

ឆ្លងកាត់រយៈពេលជាច្រើនសតវត្សន៍ ស្ថាបត្យកម្មពីរ៉ាមីតត្រូវបានវិវឌ្ឍបន្តិចម្ដងៗ ពីសំណង់ពីរ៉ាមីតដែលមានរាងជាជណ្ដើរបែបសាមញ្ញ ទៅកាន់សំណង់ពីរ៉ាមីតដែលមានរាងបែបជាសាជី មានកម្ពស់ខ្ពស់សន្ធឹម ហើយដែលមានជ្រុងទាំងអស់រាបស្មើ ។



**ពីរ៉ាមីតជណ្ដើរ ឬហៅម្យ៉ាងទៀតថា ពីរ៉ាមីតនៃដ្យូស៊ើរ (ស្ថាបត្យកម្មដំបូងនៃ ពីរ៉ាមីត) បង្កើតឡើងនៅក្នុងឆ្នាំ ២៦៣០ ដល់ ២៦១១មុន គ.ស កម្ពស់៦២ម៉ែត្រ**

នៅពេលស្ថាបនារួចដំបូង ពីរ៉ាមីតមានកម្ពស់១៤៥.៧៥ម៉ែត្រ ប៉ុន្តែឆ្លងកាត់រយៈពេលជាច្រើនឆ្នាំ កម្ពស់របស់វាថយមកនៅត្រឹម ១៣៥.៧៥ម៉ែត្រប៉ុណ្ណោះ (បាត់អស់១០ម៉ែត្រ)។ អាស្រ័យដោយកម្ពស់ដ៏ខ្ពស់របស់វានេះឯងហើយ ទើបអស់រយៈពេលជាង៤៥សតវត្សន៏(រហូតមកទល់ស.តទី១៩) ដែលពីរ៉ាមីតឈរបង្ហួតរាងយ៉ាងសង្ហារ ក្នុងនាមជាស្ថាបត្យកម្មសំណង់ ដែលមានកម្ពស់ខ្ពស់ជាងគេបំផុត នៅលើភពផែនដី។ មុំទ្រេតនៃជ្រុងនិមួយៗរបស់ពីរ៉ាមីត មានកម្រិត៥១ដឺក្រេ ហើយត្រូវបានកំណត់ទិសដៅយ៉ាងត្រឹមត្រូវ ជាមួយនឹងចំណុចដ៏ជាក់លាក់មួយនៃត្រី

វិស័យ ទាក់ទងទៅនឹងទិសធំៗទាំង៤។ បាតផ្នែកខាងក្រោម នៃជ្រុងទាំង៤របស់វា គឺមានប្រវែងស្មើគ្នា ហើយជ្រុងនិមួយៗ (គិតចាប់ពីផ្ទៃដីរហូតដល់កំពូល) មានប្រវែង២២៩ម៉ែត្រ (កម្ពស់១៣៥.៧៥ម៉ែត្រ) ប៉ុន្តែអ្វីដែលគួរឱ្យភ្ញាក់ផ្អើលនោះគឺនៅត្រង់ថា ប្រវែងនៃជ្រុងនិមួយៗរបស់វា (ចាប់ពីផ្ទៃដីរហូតដល់កំពូល) មានភាពវែងខ្លីជាងគ្នាត្រឹម0.១% (0.២៣ម៉ែត្រ)ប៉ុណ្ណោះ។ តួប្រាង្គពីរ៉ាមីតទាំងមូលត្រូវបានផ្គុំឡើងដោយផ្ទាំងសិលាចំនួន២.៣លានដុំ ហើយដែលមួយដុំៗមានទម្ងន់ប្រហែល២.៥តោន។ បើតាមការប៉ាន់ស្មាន ចំនួនដុំថ្មដែលប្រើក្នុងការកសាងពីរ៉ាមីតចំនួន៣ គឺគេអាចយកវាទៅកសាងជាកំពែង ដែលមានកម្ពស់៣ម៉ែត្រ និងកម្រាស់0.៣ម៉ែត្រ ព័ទ្ធជុំវិញប្រទេសបារាំងទាំងមូលបាន រីឯក្រលាផ្ទៃដែលគ្របដណ្តប់ដោយមហាពីរ៉ាមីតនោះ បើប្រៀបធៀបទៅគឺវាមានទំហំស្មើនឹង ការរួមបញ្ចូលគ្នានៃមហាវិថីផេតធើរ៍(Peter) នៅក្នុងទីក្រុងរ៉ូមរបស់អ៊ីតាលី ព្រះវិហារទាំងអស់នៅក្នុងទីក្រុងផ្លរ៉េន ក្រុងមីឡាន និងក្រុងវ៉េស្តមីនសធើរ៍ រួមទាំងមហាវិថីផលស៍នៅក្នុងទីក្រុងឡុងផងដែរ។ ច្រកចូលទៅក្នុងពីរ៉ាមីត គឺស្ថិតនៅទិសខាងជើង ដោយយើងអាចធ្វើដំនើរ ចូលទៅតាមច្រកធម្មតា តាមរបៀង ឬតាមរូងក្រោមដីដែលផ្លូវនិមួយៗនឹងនាំយើងឆ្ពោះទៅកាន់ បន្ទប់បញ្ចុះព្រះសពរបស់មហាក្សត្រអេហ្ស៊ីបសម័យបុរាណ ឬបន្ទប់សម្រាប់ប្រើប្រាស់ក្នុងពិធីផ្សេងៗ។ បន្ទប់បញ្ចុះសពរបស់ស្តេចអេហ្ស៊ីប មានទីតាំងស្ថិតនៅចំចំណុចកណ្តាលនៃតួពីរ៉ាមីត ដែលគេអាចចូលទៅដល់បាន តាមរយៈរបៀងធំ ហើយនិងផ្លូវឡើងមួយ។ មឈូស (សព្វថ្ងៃឃើញមាននៅសល់តែមឈូសទទេប៉ុណ្ណោះ) តម្កល់សពរបស់ស្តេចអេហ្ស៊ីប ត្រូវ




**ពីរ៉ាមីតថ្នាក់មធ្យម**




**ពីរ៉ាមីតកោង**

បានធ្វើឡើងដោយសិលាក្រានីតពណ៌ក្រហម ដូចគ្នាទៅនឹងផ្នែកខាងក្នុងនៃបន្ទប់បញ្ចុះព្រះសពរបស់ព្រះអង្គផងដែរ ។ ភាពទាក់ទាញបំផុត គឺនៅលើសិលាដែលមានគែមស្រួចស្ថិតនៅលើទ្វារចូល ហើយដែលមានប្រវែងជាង៣ម៉ែត្រ កម្ពស់២.៤ម៉ែត្រ និងកម្រាស់១.៣ម៉ែត្រ។ គ្រប់ផ្ទាំងសិលាទាំងអស់ គឺត្រូវបានរៀបតម្រឹមយ៉ាងស្មើផង សូម្បីតែបៀមួយសន្លឹក ក៏មិនអាចស៊កបញ្ចូលទៅក្នុងមុខតំណនោះបានឡើយ ។ មឈូសថ្មត្រូវបានដាក់យ៉ាងស្របទៅនឹងចំណុចនៃត្រីវិស័យ ហើយមានទំហំតូច..ច..ច..ជាងត្រឹម១សង់ទីម៉ែត្រប៉ុណ្ណោះ ធៀបទៅនឹងទ្វារនៃបន្ទប់បញ្ចុះព្រះសព ។ តាមរយៈការប៉ាន់ស្មាន វាប្រហែលជាត្រូវបានគេនាំចូលមកនៅពេលដែលសំណង់ទាំងមូលកំពុងសាងសង់ ។




**ជ្រុងមួយនៃមហាពីរ៉ាមីតឃូហ្វ៊ូ**

តើពីរ៉ាមីតត្រូវបានសាងឡើងមកដើម្បីអ្វី? ឆ្លើយតបទៅនឹងការចោទសួរនេះ មានទ្រឹស្តីថ្មីៗជាច្រើនទាក់ទងទៅនឹងដើមកំណើត និងគោលបំណងនៃការកសាងពីរ៉ាមីតនៅហ្គីហ្សា ខ្លះថាពីរ៉ាមីតត្រូវបានសាងឡើង ដោយយោងតាមដំនើរគោចរនៃតារាវិថី ខ្លះថាជាកន្លែងមើលផ្កាយ កន្លែងសម្រាប់ធ្វើពិធីកម្មខាងសាសនា កន្លែងសម្រាប់គោរពបូជា ក្នុងខណៈដែលខ្លះទៀតអះអាងថា ជាទីសម្រាប់តម្កល់សពរបស់ហ្វារ៉ូ ( ស្តេចអេហ្ស៊ីបបុរាណ)..... ។ល ។

សូម្បីតែទ្រឹស្តីជាច្រើន ដែលពាក់ព័ន្ធជាមួយនឹងរឿងក្រៅភពផែនដី ក៏ត្រូវបានស្នើឡើងជាមួយនិងអំណះអំណាង ដែលមិនសូវទទួលបាននូវការគាំទ្រប៉ុន្មាន ។ ទុកជាយ៉ាងដូច្នោះក្តី ជំនឿទៅលើអំណាចដែលគ្របសង្កត់លើវិទ្យាសាស្ត្រ និងព័ស្តុតាងផ្នែកប្រវត្តិសាស្ត្រ( ជំនឿអរូបិយ) នៅតែអះអាងទៅដល់ការសរុបយ៉ាងដូច្នោះ( ដូចជាជឿថាអាទិទេពជាអ្នកកសាងឡើងជាដើម) ។

ចំពោះប្រវត្តិមួយចំនួនទាក់ទងទៅនឹងមហាពីរ៉ាមីតនេះ គឺត្រូវបានសរសេរឡើងជាលើកដំបូង ដោយប្រវត្តិវិទូក្រិចឈ្មោះថា**ហេរ៉ូ ដូទូស** (Herodotus) ។ គាត់បានធ្វើទស្សនកិច្ចទៅកាន់អេហ្ស៊ីប ក្នុងកំឡុងឆ្នាំ៤៥០មុនគ.ស ហើយបានធ្វើការកត់ត្រាទុកនូវរឿងរ៉ាវទាក់ទងទៅនឹងពីរ៉ាមីត ក្នុងសៀវភៅប្រវត្តិសាស្ត្ររបស់គាត់ ។ ពតិមានដែលគាត់ទទួលបាន ពីមគ្គុទេសក៏ជនជាតិអេហ្ស៊ីបនោះគឺថា ពីរ៉ាមីតត្រូវប្រើរយៈពេលអស់២០ឆ្នាំក្នុងការសាងសង់ ដោយប្រើកម្លាំងពលកម្ម ដែលជាទាសករចំនួន១សែននាក់ ហើយផ្ទាំងថ្មទាំងអស់ត្រូវបានលើកឡើងដាក់បញ្ចូលទៅក្នុងប្លង់និមួយៗ ដោយការប្រើនូវគ្រឿងចក្រដ៏ធំ ។




រូបភាពបង្ហាញច្រកសំខាន់ផ្សេងៗនៅក្នុងមហាពីរ៉ាមីត
១. ច្រកចូល ២. និង ៣. ជាបន្ទប់បញ្ចុះព្រះសព
៤. របៀងវែង ៥. បន្ទប់តម្កល់ព្រះសព

ក្នុងឆ្នាំ១៦៣៨ គណិតវិទូជនជាតិអង់គ្លេសឈ្មោះចន ហ្គ្រីវស៊ី (John-Greaves) បានធ្វើដំណើរទៅកាន់អេហ្ស៊ីប ។ គាត់បានរកឃើញផ្លូវរូងអាថ៌កំបាំងដ៏តូចមួយ ជាប់នឹងជញ្ជាំងចូលទៅកាន់ពីរ៉ាមីត ដែលតភ្ជាប់ទៅនឹងរបៀងដ៏ធំនៅខាងក្នុងតួពីរ៉ាមីត ជាមួយច្រកចុះមកក្រោម (សូមពិនិត្យមើលរូបខាងលើ) ។ ច្រកទាំង២ត្រូវបានបិទភ្ជិតយ៉ាងណែន ហើយបាតក្រោមរបស់វាក៏ពេញទៅដោយកំទេចកំទី ។ ផ្អែកលើការសន្និដ្ឋានរបស់អ្នកបុរាណវិទ្យាមួយចំនួន ផ្លូវនេះទំនងត្រូវបានប្រើជាលើកចុងក្រោយបំផុត ដោយមនុស្សរបស់ស្ដេចអេហ្ស៊ីប(រាជបរិពារ) ដើម្បី

ចេញពីក្នុងផ្នូរបញ្ចុះព្រះសព ដែលបន្ទាប់មកត្រូវបានរាំងខ្ទប់ដោយសិលាក្រានីត ដើម្បីការពារពពួកចោរដែលមានបំណង ចូលទៅលួចយករតនសម្បត្តិ ។



គំនិតខាងលើនេះពិតជាមិនខុសឡើយ ដ្បិតថាតាំងពីសម័យបុរាណរៀងមក ពីរ៉ាមីតត្រូវបានឈ្លានពានដោយពពួកចោរជាច្រើនលើកច្រើនសា ពិសេសគឺនៅក្នុងឆ្នាំ៨២០នៃគ.ស ព្រះចៅអារ៉ាប់**កាលីហ្វ អាប់ឌុលឡាហ៏** (the Arab Caliph Abdullah Al Manum) បានខិតខំព្យាយាមរុករករតនសម្បត្តិនៅក្នុងមហាពីរ៉ាមីតនេះដែរ ប៉ុន្តែជាលទ្ធផលគឺព្រះអង្គមិនបានទទួលនូវអ្វីទាំងអស់ ។ ទាំងនេះពួកអ្នកបុរាណវិទ្យាទាំងឡាយ នាំគ្នាសរុបសេចក្តីថា គឺដោយសារតែភាពឆ្លាតវាងវៃរបស់ស្ថាបត្យករ ដែលបានត្រៀមការទុកស្រេចជាមុន ។

បើគេសង្កេតតាមច្រកចូលដ៏តូចចង្អៀត និងកំទេចកំទីដ៏ច្រើន វាមើលទៅហាក់មិនសមជាទីកន្លែង ដែលបង្កប់ទៅដោយរតនសម្បត្តិដ៏មហាសាល បូករួមទាំងមឈូសថ្មដ៏ធំ ដែលគេអាចលើករំកិលឆ្លងកាត់ទីនេះបានឡើយ ។ មានមនុស្សខ្លះយល់ឃើញថាពីរ៉ាមីតគឺមិនត្រូវបានសាងឡើង សម្រាប់ទុកជាទីតម្កល់សពនោះទេ

ប៉ុន្តែផ្ទុយទៅវិញ វាគ្រាន់តែជាទីដែលគេស្ថាបនាឡើង សម្រាប់មើលអំពីដំណើរគោចរនៃតារាវិថីប៉ុណ្ណោះ។ យោងទៅតាមលោក**រីឆាត ប្រ៊ុកទ័រ** (RichardProc-tor) ដែលជាអ្នកឯកទេសខាងតារាសាស្ត្របានសន្និដ្ឋានថា ច្រកចុះមកខាងក្រោមអាចត្រូវបានប្រើ ដើម្បីសង្កេតពិនិត្យដំនើរឆ្លងកាត់របស់ហ្វូងតារា។ បន្ថែមពីលើនោះ លោករីឆាតនៅបានសន្និដ្ឋានថា ច្រករបៀងដ៏ធំអាចត្រូវបានប្រើសម្រាប់ការគូសវាសផែនទី ស្តីពីគន្លងនៃវិថីរបស់តារា។ យ៉ាងណាក៏ដោយចុះ ភាគច្រើននៃអ្នកបុរាណវិទ្យាយល់ស្របចំពោះទ្រឹស្តីដែលថា មហាពីរ៉ាមីតគឺពិតណាស់ ត្រូវបានសាងឡើងទៅតាមប្រពៃណី ដែលទុកដាក់ដូចជាផ្នូរតម្កល់សពរបស់ហ្វារ៉ូនៃអេហ្ស៊ីប។



**ច្រកមួយក្នុងចំណោមច្រកជាច្រើននៅក្នុងមហាពីរ៉ាមីត**

ប្រសិនបើដូច្នោះមែន ហេតុអ្វីបានជាគេមិនឃើញមានសាកសពរបស់អង្គហ្វារ៉ូ នៅក្នុងបន្ទប់ដែលគេអះអាងថាជាបន្ទប់តម្កល់ព្រះសពនោះ? តើមានអ្វីកើតឡើងចំពោះម៉ាំមី (សាកសពដែលបានឆ្លងកាត់បច្ចេកទេសក្នុងការរក្សាទុក ដោយមិនឱ្យស្អុយរលួយបាន) និងសម្បត្តិទាំងឡាយរបស់អធិរាជ ឃូហ្វូ (អធិរាជដែលបានកសាងនូវមហាពីរ៉ាមីតដ៏ធំជាងគេបង្អស់)?




**ដំណើរទេសចរណ៍របស់អ្នកទៅកាន់អេហ្ស៊ីបនឹងរឹតតែអស្ចារ្យថែមទៀត ប្រសិនបើបានជិះអូដ្ឋកំសាន្តនៅលើវាលខ្សាច់នៃមហាពីរ៉ាមីត( ដូចក្នុងរូបខាងលើ)**

គ្មាននណារម្នាក់អាចផ្តល់ចម្លើយចំពោះសំនួរនេះបានឡើយ ព្រោះថារាល់ការរុករកស្រាវជ្រាវទាំងឡាយ នៅតែមិនទាន់អាចស្វែងរកឃើញនូវទីបញ្ចុះព្រះសព ( អ្នកស្រាវជ្រាវមួយចំនួនជឿថា សាកសពម៉ាំមីរបស់ហ្វារ៉ូឃូហ្វ៊ូ និងសម្បត្តិទាំងឡាយរបស់ព្រះអង្គ ត្រូវបានចោរលួចយកទៅអស់ហើយ ក្នុងខណៈដែលមួយចំនួនទៀតអះអាងថា បន្ទប់បញ្ចុះព្រះសព ព្រមជាមួយនិងមឈូសថ្ម ដែលគេបានរកឃើញនោះ គឺមិនមែនជាទីកន្លែងបញ្ចុះព្រះសពពិតប្រាកដនោះទេ គឺថាព្រះសពរបស់ហ្វារ៉ូអាចនឹងត្រូវគេបញ្ចុះ នៅក្នុងបន្ទប់អាថ៌កំបាំងណាមួយផ្សេងទៀត នៅក្នុងមហាពីរ៉ាមីតឃូហ្វ៊ូនេះ ជាក់ជាមិនខាន) ឬច្រកណាមួយផ្សេងទៀតឡើយ( ពីរ៉ាមីតដ៏ទៃត្រូវគេរកឃើញស្លាកស្នាម និងព័ស្តុតាងជាច្រើនហើយ) ។

បច្ចុប្បន្ននេះមហាពីរ៉ាមីតរួមជាមួយពីរ៉ាមីតទាំងឡាយដ៏ទៃទៀត រួមទាំងរូបសំណាកនរសិង្ហ( សំណាកដែលមានក្បាលជាមនុស្សឬជាសត្វផ្សេងៗប៉ុន្តែមានខ្លួនជាសត្វសិង្ហ) ត្រូវបានព័ទ្ធរបង នៅក្នុងតំបន់ទេសចរណ៍នៃវាលរាបហ្គីហ្សា ដូចគ្នាទៅនឹងសារមន្ទីរនាវាព្រះអាទិត្យ ដែលជាទីកន្លែងតម្កល់នូវនាវា ដែលត្រូវបានគេរកឃើញនៅក្នុងឆ្នាំ១៩៥៤ ជិតជ្រុងខាងត្បូងនៃមហាពីរ៉ាមីត។ គឺនាវានេះឯងហើយដែល គេជឿថាប្រៀបដូចជាយានចម្លងហ្វារ៉ូទៅកាន់ពិភពថ្មី ក្រោយការចូលទីវង្គត់របស់ព្រះអង្គ ហើយធ្លាប់ត្រូវបានប្រើប្រាស់សម្រាប់តម្កល់( ដឹក) ព្រះសពរបស់ហ្វារ៉ូ ឃូហ្វ៊ូ ក្នុងដំណើរជាលើកចុងក្រោយបំផុតរបស់ព្រះអង្គនៅលើផែនដី មុនពេលរាងកាយរបស់ព្រះអង្គ ត្រូវគេបញ្ចុះទៅក្នុងមហាពីរ៉ាមីត។

✲✲✲✲✲✲✲✲✲




- ឈ្មោះ : ឧទ្យានបណ្តែតបាប៊ីឡូន
- ទីតាំង : ៥០គ.ម ខាងត្បូងក្រុងបាក់ដាត ប្រទេសអ៊ីរ៉ាក់
- ឆ្នាំកសាង : ៦០៤មុនគ.ស
- កសាងដោយ : អធិរាជ នេប៊ូ ឆាដនិសហ្សារ៍
- វត្ថុបំណង : ជាទីប្រថាប់នៃមហេសីរបស់ព្រះអង្គ

-បច្ចុប្បន្នបន្សល់ទុកត្រឹមខឿនសំណង់បាក់បែកប៉ុណ្ណោះ ( រងគ្រោះដោយការរញ្ជួយដី)

ពោរពេញទៅដោយផលានុផលនានា និងផ្កាចំរុះពណ៌ដែលជះក្លិនពិដោរ ក្រអូបឈ្ងុយឈ្ងប់ បូករួមជាមួយសម្រស់ទឹកធ្លាក់ដែលមានសម្លេងពិរោះរណ្ដំ ព្រមទាំងសត្វប្លែកៗ ដែលគេកម្របានជួបក្នុងទីដទៃ ឧទ្យានដែលត្រូវបានសាងឡើងនៅលើទីទួលនៃព្រះបរមរាជវាំង.......ទាំងនេះគឺជារូបភាពនៃឧទ្យានបណ្ដែតបាប៊ីឡូន ឧទ្យានដែលស្ថិតនៅក្នុងក្ដីស្រមើស្រមៃរបស់មនុស្សជាច្រើន។ វាប្រហែលជាគួរឱ្យភ្ញាក់ផ្អើលមិនតិចទេ នៅពេលដែលយើងដឹងថា ឧទ្យានដែលមានសម្រស់ល្អឯកយ៉ាងដូច្នេះ ហើយដែលយើងធ្លាប់គិតថា វាប្រហែលជាមិនមាននៅក្នុងលោករបស់យើងនេះឡើយ លើកលែងតែនៅក្នុងក្ដីស្រមើស្រមៃ របស់ពួកកវីនិពន្ធ និងមនុស្សមួយចំនួនដែលចូលចិត្តបណ្ដែតអារម្មណ៍ ទៅតាមមនោសញ្ចេតនានៃការនឹកគិតរបស់ពួកគេប៉ុណ្ណោះ ប៉ុន្តែវាគឺជាការពិត (វាមានពិត)........!!

វាមានទីតាំងស្ថិតនៅត្រើយខាងកើត នៃទន្លេយូប្រេ្វតស៍ចម្ងាយប្រហែល ៥០គ.ម ពីទីក្រុងបាក់ដាតនៃប្រទេសអ៊ីរ៉ាក់។ ឧទ្យានបាប៊ីឡូនអតីត ស្ថិតនៅក្នុងទីក្រុងបាប៊ីឡូនបុរាណ ក្រោមការគ្រប់គ្រងរបស់ព្រះចៅអធិរាជនេប៊ូឆាដ និសហ្សារ៍ (Nebuchadnezzar) ទី២ (៦០៤ដល់៥៦២មុនគ.ស) វាបានធ្វើឱ្យមានការកោតស្ញប់ស្ញែង ពីសំណាក់អ្នកទេសចរទាំងឡាយ ដែលបានទៅឃើញផ្ទាល់នឹងភ្នែករបស់ពួកគេ។

បើយោងទៅតាមបទពណ៌នា ដែលសរសេរដោយលោកហេរ៉ូ ដូទូស (Herodotus) ប្រវត្តិវិទូសញ្ជាតិក្រិចនៅឆ្នាំ៤៥០មុនគ.ស អតីតរាជធានីបាប៊ីឡូន គឺមានសម្រស់ស្រស់ស្អាត លើសរាជធានីណាៗទាំងអស់លើលោក(នាយុគសម័យនោះ)។



**បើស្អាតយ៉ាងនេះហើយមិនជាប់ជាអច្ឆរិយវត្ថុទៀតនោះ ក៏មិនដឹងថាយ៉ាងម៉េចទៀតទេ**

..........................................................................................................

វាមានកំពែងផ្នែកខាងក្រៅ ដែលមានបណ្តោយប្រវែង៩០គ.ម កម្រាស់(ទទឹង) ២៤ម៉ែត្រ និងកម្ពស់៩៧.៥ម៉ែត្រ (ទំហំនេះគឺល្មមនឹងអាចឱ្យរទេះសេះ៤បត់នៅលើមហាកំពែងនោះបាន)។ ចំណែកឯកំពែងផ្នែកខាងក្នុង គឺមិនក្រាស់ដូចជាផ្នែកខាងក្រៅ(២៤ម៉ែត្រ)នោះទេ ប៉ុន្តែវាមានភាពរឹងមាំយ៉ាងខ្លាំង។ នៅផ្នែកខាងក្នុងនៃមហាកំពែងទាំងនោះមានបន្ទាយ និងប្រាសាទជាច្រើន ដែលតម្កល់នូវមហាបដិមាជាច្រើនធ្វើអំពីមាស។ បើគេចោលភ្នែកសម្លឹងមើលទៅលើអាកាស គេនឹងឃើញប៉មមួយ ដែលលេចខ្ពស់ត្រដែតឡើងផុតពីទីក្រុង ជាប៉មដែលមានឈ្មោះល្បីល្បាញហៅថាប៉ម **បាប៊ែល** (Tower of Babel) ដែលត្រូវបានឧទ្ទិសទុកដូចជា ប្រាសាទសម្រាប់អាទិទេព**ម៉ាឌុក** ហើយដែលកម្ពស់របស់វាធ្វើឱ្យគេមើលឃើញថា ហាក់ដូចជាខ្ពស់ជិតទៅនឹងស្ថានទេវលោក។



somano_khmer@yahoo.com

គំនូរបង្ហាញពីសម្រស់ដ៏ស្រស់ស្អាតរបស់ឧទ្យានបណ្តែតបាប៊ីឡូន




**វិចិត្រករមួយចំនួនគិតថាឧទ្យានបណ្តែតគួរតែមានលក្ខណៈបែបនេះឯង**

ដោយឡែកការស្រាវជ្រាវផ្នែកបុរាណវិទ្យា គឺបានជំទាស់ទៅនឹងអំណះអំណាងមួយចំនួនរបស់ហេរ៉ូ ដូទូស(កំពែងខាងក្រៅមានប្រវែងបណ្តោយប្រហែលត្រឹម១៦គ.ម ហើយមិនខ្ពស់ដូចការរៀបរាប់របស់ហេរ៉ូនោះទេ) ទុកជាយ៉ាងដូច្នេះក្តីបទបរិយាយរបស់គាត់ ក៏នៅតែគួរឱ្យចាប់អារម្មណ៍ ព្រោះថាបានផ្តល់ឱ្យមនុស្សជំនាន់ថ្មី បានដឹងអំពីលក្ខណៈទ្រង់ទ្រាយ ដ៏គួរឱ្យកោតស្ញប់ស្ញែងរបស់ទីក្រុងបាប៊ីឡូនបុរាណ ប៉ុន្តែអ្វីដែលធ្វើឱ្យគេចម្លែកចិត្តបំផុតនោះ នៅត្រង់ថាប្រវត្តិវិទូក្រិចរូបនេះ មិនបាននិយាយសូម្បីតែបន្តិច ស្តីអំពីឧទ្យានបណ្តែតដែលមានសម្រស់យ៉ាងល្អឯកគ្មានពីរ នោះគឺឧទ្យានបណ្តែតបាប៊ីឡូន ឧទ្យានដែលគេចាត់បញ្ចូលជាអច្ឆរិយវត្ថុមួយ ក្នុងចំណោមអច្ឆរិយវត្ថុទាំង៧ក្នុងលោក ។ បើតាមឯកសារប្រវត្តិសាស្ត្របានឱ្យដឹងថា ឧទ្យាននេះត្រូវបានសាងឡើង ក្នុងរជ្ជកាលនៃព្រះចៅនេប៊ូឆាដ និសហ្សារ៍ (Nebuchadnezzar)ទី២ ដែលគ្រប់គ្រងរាជធានីបាប៊ីឡូនអស់រយៈពេល៤៣ឆ្នាំ ចាប់ពីឆ្នាំ៦០៤មុនគ.ស (ផ្ទុយនឹងការយល់ឃើញមួយចំនួនតូចដែលអះអាងថា បាប៊ីឡូនត្រូវបានសាង

ឡើងដោយព្រះរាជនីសេមី រ៉ាមីស (Semiramis) ក្នុងកំឡុងរយៈពេល៥ឆ្នាំនៃការគ្រប់គ្រងរបស់ព្រះនាង ចាប់ពីឆ្នាំ៨១០មុនគ.ស) ។

ចំពោះរឿងរ៉ាវដែលទាក់ទងទៅនឹងឧទ្យាននេះ មានសេចក្តីតំណាលថា ព្រះនាងអាមីអ៊ីស ទីស(Amyistis) បុត្រីរបស់ព្រះចៅមេដេស បានរៀបអភិសេកជាមួយនឹងព្រះចៅនេប៊ូឆាដ និសហ្សារ៍ ក្នុងគោលបំណងចងភ្ជាប់សម្ព័ន្ធមេត្រីភាពរវាងនគរទាំង២ ជានិច្ចជាកាលទ្រង់តែងនឹករលឹកទៅដល់ ព្រះមាតុនគររបស់ព្រះនាង ហើយដែលតែងតែធ្វើឱ្យព្រះនាង ទ្រង់មានសេចក្តីសោកសៅនៅក្នុងព្រះទ័យ ។ ការណ៍នេះឯងដែលញ៉ាំងឱ្យព្រះចៅនេប៊ូឆាដ និសហ្សារ៍ទ្រង់សំរេចព្រះទ័យចេញព្រះរាជបញ្ជារឱ្យសាងសង់ឡើងនូវឧទ្យាន ដែលមានរចនាបីដូចទៅនឹងទេសភាពនៃព្រះមាតុនគររបស់ព្រះនាង ដើម្បីទុកសម្រាប់ជាទីលំហែរព្រះកាយ និងជួយបន្ធូរបន្ថយការនឹករលឹកទៅដល់ស្រុកកំណើតរបស់ព្រះនាង ។




រូបភាពនេះ ផ្អែកលើព័ស្តុតាងដែលបានមកតាមរយៈការធ្វើកំណាយធ្វើឱ្យអ្នកបុរាណវិទ្យាមួយចំនួនជឿថា ឧទ្យានបណ្តែតគួរតែមានរូបរាងបែបនេះជាងបែបណាៗទាំងអស់

"ឧទ្យានបណ្តែត" ពាក្យនេះមិនមែនមានន័យថា ឧទ្យាននេះត្រូវបានគេស្ថាបនាឡើងនៅលើនាវា ហើយបណ្តែតនៅលើផ្ទៃទឹក ឬត្រូវបានគេចងព្យួរទៅនឹងខ្សែរពួរធំៗ ដូចជាស្ពានយោលនោះទេ ប៉ុន្តែពាក្យនេះគឺមានប្រភពមកពីការបកប្រែមិនច្បាស់ ចេញពីភាសាក្រិចថា "Kremastos" ឬពី ភាសាឡាតាំងថា "Pensilis" ដែលមិនមែនមានន័យថា "បណ្តែត" ឬ "ព្យួរ" នោះទេផ្ទុយទៅវិញ គឺមានន័យថា "លយចេញ" ឬ "ផុសឡើង" ក្នុងន័យដែលវាត្រូវបានគេសាងឡើងនៅលើទីទួលប៉ុណ្ណោះ ។

នៅសតវត្សន៍ទី១មុនគ.ស លោកស្ត្រាបូ (Strabo) ភូមិវិទូជនជាតិក្រិចធ្លាប់បានធ្វើការពិពណ៌នាអំពីឧទ្យានបាប៊ីឡូន ទុកយ៉ាងដូច្នេះថា "ឧទ្យានបាប៊ីឡូនត្រូវបានសាងឡើងជាច្រើនជាន់ថ្នាក់ ដែលថ្នាក់និមួយៗត្រូវបានលើកទ្រឡើងដោយសសរស្តម្ភមានរាង៦ជ្រុង ហើយត្រូវបានចាក់បំពេញដោយដី ដើម្បីជាប្រយោជន៍ក្នុងការដាំដើមឈើធំៗ ព្រមទាំងរុក្ខជាតិនិងផ្កាផ្សេងៗ ។ ពិដាននៃថ្នាក់និមួយៗត្រូវបានស្ថាបនាឡើង ដោយឥដ្ឋលាយនឹងកៅស៊ូ" ។

ដោយឡែកលោកដ្យូដូរ៉ាស់ ស៊ីគូឡាស (Diodorus Siculus) ប្រវត្តិវិទូជនជាតិក្រិច បានធ្វើកំណត់ត្រាទុកថា " ពិដានផ្ទាល់ដីត្រូវបានក្រាលដោយបន្ទះនៃផ្ទាំងថ្មដ៏ធំ ហើយក្រាលពីលើ ដោយកៅស៊ូហើយនិងក្បឿង ។ រីឯបាតនៃពិដានផ្នែកខាងលើទាំងអស់ ត្រូវបានក្រាលដោយផ្ទាំងសំណរជាច្រើន ដើម្បីការពារការជ្រាបទឹកពីដី នៅខាងលើដែលអាចបំផ្លាញ ដល់ខឿនរបស់សំណង់ ។ ផ្នែកខាងលើនៃផ្ទាំងសំណរទាំងនោះ ត្រូវបានចាក់បំពេញដោយដីយ៉ាងច្រើន ដែលល្មមអាចនឹងធានា



សម្រស់ទីក្រុងបាប៊ីឡូនបុរាណ គូរដោយវិចិត្រករសម័យបច្ចុប្បន្ន



រូបមួយផ្សេងទៀត បង្ហាញពីភាពសម្បូររុងរឿងនៃទីក្រុងបាប៊ីឡូនបុរាណ

ដល់ការចម្រើនលូតលាស់ របស់ដើមឈើធំៗបាន ។ នៅពេលដីត្រូវបានគេចាក់បំពេញរួចរាល់ និងធ្វើឱ្យវារាបស្មើ រុក្ខជាតិគ្រប់ប្រភេទត្រូវបានបណ្តុះ ក្នុងបំណងធ្វើឱ្យឧទ្យានប្រកបទៅដោយ ទស្សនីយភាពដ៏ស្រស់ត្រកាល ប្រៀបបានទៅនឹងទេសភាពនៃព្រះមាតុនគរ របស់ព្រះនាងអាមី អ៊ីសទីស " ។

តើឧទ្យានបណ្តែតបាប៊ីឡូនមានទំហំប៉ុណ្ណា? ដ្យូដូរ៉ាស់បានសរសេរទុកថា ", វាមានទទឹងប្រវែង១២២ម៉ែត្រ បណ្តោយប្រវែង១២២ម៉ែត្រ( មានរាងការេ)និងកម្ពស់២៤ម៉ែត្រ " ។ តាមរយៈឯកសារដ៏ទៃទៀតបានបញ្ជាក់ឱ្យដឹងថា វាមានកម្ពស់ប្រហាក់ប្រហែលទៅនឹង កម្ពស់នៃកំពែងផ្នែកខាងក្រៅ (កំពែងដែលហេរ៉ូ ដូទូសបានកត់ត្រាទុកថា មានកម្ពស់៩៧.៥ម៉ែត្រ) ។




**នេះក៏ជាលក្ខណៈមួយផ្សេងទៀត នៃឧទ្យានបណ្តែតដ៏ល្បីល្បាញ ដែលអ្នកបុរាណវិទ្យាមួយចំនួនបានអះអាង**

មានបទបរិយាយជាច្រើន ដែលសរសេរទាក់ទងទៅនឹងឧទ្យានបាប៊ីឡូន ដោយភាគច្រើននៃបទបរិយាយទាំងនោះ បានប្រៀបប្រដូចឧទ្យាននេះ ថាជាឧទ្យាន ដែលមានទស្សនីយភាពដ៏ល្អប្លែកចម្លែកភ្នែក ខុសពីឧទ្យានណា១ទាំងអស់ ជាឧទ្យានបៃតង.....ជាឧទ្យានសម្បូរណ៍ទៅដោយរុក្ខជាតិច្រើនប្រភេទ....... មានភ្នំសិប្បនិម្មិតផុសឡើងនៅកណ្ដាលទីវាបស្មើ.... ។ល។ ក្រៅអំពីសម្រស់ដ៏ស្រស់ស្អាតរបស់វា បាប៊ីឡូននៅបានបង្ហាញឱ្យឃើញពី អំណាចនិងឥទ្ធិពលដ៏ខ្លាំងក្លា នៃអាណាចក្របាប៊ីឡូនបុរាណ ក្រោមការគ្រប់គ្រងរបស់ព្រះចៅអធិរាជនេប៊ូឆាដ និសហ្សារ៉ ទ្រង់ជាមហាក្សត្រដ៏ឆ្នើម ដែលព្រះអង្គមិនត្រឹមតែបានសាង នូវឧទ្យានដ៏ស្រស់ស្អាតបំផុត នៅលើពិភពលោកប៉ុណ្ណោះទេ តែទ្រង់នៅបានសាងនូវសមិទ្ធផល ដ៏គួរឱ្យកោតស្ញប់ស្ញែងជាច្រើនផ្សេងទៀត ដូចជាប្រាសាទ រាជវាំង មហាកំពែង និងមហាវិថីជាច្រើន ។

តើឧទ្យានបណ្ដែតបាប៊ីឡូនដែលថានេះ ពិតជាមានមែនឬ? មិនមានការឆ្លើយតបណាមួយពីសំណាក់ហេរ៉ូ ដូទូស ចំពោះសំណួរខាងលើនេះទេ ហើយសំណួរដដែលនេះឯង ត្រូវបានចោទសួរដោយ អ្នកបុរាណវិទ្យាអាល្លឺម៉ង់រ៉ូប៊ើត កុលដេវៃ (Robert Koldewey) ក្នុងឆ្នាំ១៨៩៩។ គាត់បានចំណាយពេល១៤ឆ្នាំដើម្បីស្វែងរកចម្លើយចំពោះសំនួរខាងលើ តាមរយៈការធ្វើកំណាយ ទៅលើតំបន់សំខាន់១មួយចំនួន ដោយបានរកឃើញនូវស្លាកស្នាមជាច្រើន ទាក់ទងទៅនឹងមហាកំពែងផ្នែកខាងក្រៅ និងកំពែងផ្នែកខាងក្នុង ព្រមទាំងខឿននៃប៉មបាប៊ែល ព្រះរាជវាំងរបស់ស្ដេចនេប៊ូឆាដ និសហ្សារ៉ និងផ្លូវសម្រាប់ដង្ហែរក្បួនស្ថិតនៅចំកណ្ដាលនៃទីក្រុង ។

ខណៈកំពុងធ្វើការជីករុករក នូវបន្ទាយប្រាការជ្រុងខាងត្បូង គាត់បានប្រទះឃើញនូវអគារជាន់ក្រោមបំផុត ដែលមានបន្ទប់ធំៗចំនួន១៤ ជាមួយនិងជញ្ជាំងថ្មដែលមានរាងកោង ។

បើផ្អែកទៅលើកំណត់ត្រា ដែលពួកប្រវត្តិវិទូសម័យបុរាណបានកត់ត្រាទុក គឺមានត្រឹមតែទីកន្លែងសំខាន់ៗចំនួន២ប៉ុណ្ណោះ ដែលត្រូវបានគេស្ថាបនាឡើងអំពីថ្ម នោះគឺបន្ទាយប្រាការនៃជ្រុងខាងជើង ហើយនិងឧទ្យានបណ្តែតបាប៊ីឡូន ។

យោងតាមការធ្វើកំណាយរបស់លោករ៉ូប៊ើត កុលដេវ៉េ បានបង្ហាញឱ្យឃើញថា ពិតជាមានបន្ទាយប្រាការនៃជ្រុងខាងជើង ដែលធ្វើអំពីថ្មប្រាកដមែន ។ ការរកឃើញនេះ វាប្រៀបបីដូចជាគាត់បានរកឃើញ នូវបន្ទប់ក្រោមដីនៃឧទ្យានបាប៊ីឡូនយ៉ាងដូច្នោះដែរ ។ ទោះជាយ៉ាងណាក្តីក៏លោក រ៉ូប៊ើត កុលដេវ៉េ នៅតែបន្តការរុករករបស់គាត់តទៅទៀត ទាំងបានប្រទះឃើញនូវស្លាកស្នាមជាច្រើនស្របទៅនឹងកំណត់ហេតុ ដែលដ្យូដូរ៉ាស់ ស៊ីគូឡាសបានកត់ត្រាទុក ហើយទីបំផុតបន្ទប់ជាច្រើនត្រូវបានរកឃើញជាបន្តបន្ទាប់ ព្រមជាមួយនិងរូងដ៏ចម្លែកជាច្រើននៅបាតក្រោម ដែលគាត់ធ្វើការសន្និដ្ឋានថា វាធ្លាប់ជាទីកន្លែងដែលគេប្រើសម្រាប់បូមទឹកបាញ់ឡើងទៅលើពិដាននៃឧទ្យានបាប៊ីឡូន ។ ខឿនសំណង់ដែលលោករ៉ូប៊ើត កុលដេវ៉េ បានរកឃើញគឺមានទំហំប្រហែលពី៣០ម៉ែត្រទៅ៤៦ម៉ែត្រ តូចជាងទំហំដែលប្រវត្តិវិទូសម័យបុរាណបានកត់ត្រាទុក ប៉ុន្តែទោះជាយ៉ាងណា វាក៏នៅតែគួរឱ្យចាប់អារម្មណ៍ ។

ថ្វីត្បិតថាបាប៊ីឡូនត្រូវបានគេស្គាល់យ៉ាងទូលំទូលាយ ដែលខុសពីទីក្រុង

បុរាណជាច្រើនផ្សេងទៀត ដែលមិនសូវមាននណារស្គាល់ក៏ដោយ ក៏វាមិនបាន បន្សល់ទុក នូវមរតកនៃស្ថាបត្យកម្មណាមួយឡើយ ។



អស់រយៈពេលជាច្រើនសតវត្សន៍ ដែលសភាពអ៊ូអរនៃអតីតកាល បានបំភ្លេចចោលទីក្រុងបុរាណ បាប៊ីឡូន ហើយជំនួសវិញដោយ ពំនូកនៃល្អងធូលី និងកំទេចកំទី ព្រមជាមួយនិងសភាពស្ងាត់ជ្រងំ (ដូចគ្នាទៅនឹងរាជធានីយសោធរ បុរៈដ៏ល្បីល្បាញរបស់អាណាចក្រ ខ្មែរនាសម័យមហានគរ ដែលត្រូវ គេបំភ្លេចចោលអស់រយៈពេលជិត ៥សតវត្សន៍ព្រមទាំងជំនួសមក វិញ ដោយសម្លេងបក្សាបក្សី និង ព្រៃឈើដែលដុះចាក់ឫសគ្រប ដណ្តប់លើទីក្រុងបុរាណមួយនេះ

**គំនរបាក់បែកនៃមហាកំពែងរបស់អតីតក្រុងបាប៊ីឡូន(រូបធំ)**
**ជាមួយនឹងខឿនបាក់បែកនៃឧទ្យានបណ្តែតបាប៊ីឡូន(រូបតូច)**
**ដែលអ្នកបុរាណវិទ្យា រ៉ូប៊ើត កុលដេវៃ បានរកឃើញតាមរយៈការធ្វើកំណាយ**




ក្បាំងមួយផ្សេងទៀតដែលបង្ហាញពីសម្រស់នៃឧទ្យានបណ្តែតបាប៊ីឡូន

មិត្តអ្នកអានមួយចំនួនអាចនឹងមានចម្ងល់ថា តើព្រះនាងអាមី អ៊ីសទីស (មហេសីរបស់ព្រះចៅនេប៊ូឆាដ និសហ្សារ៍) ទ្រង់សព្វព្រះទ័យជាមួយនឹងឧទ្យានបាប៊ីឡូន ដែលមានសម្រស់យ៉ាងល្អត្រកាលនេះរបស់ព្រះនាង ឬមួយទ្រង់នៅតែបន្តសោកសៅ ដោយក្តីនឹករឮកទៅដល់ទស្សនីយភាព នៃសម្រស់ធម្មជាតិដ៏ខៀវស្រងាត់ នៃព្រះមាតុនគររបស់ព្រះនាង.......?? ។




- ឈ្មោះ : ទេវរូបហ្សេអ៊ូស
- ទីតាំង : ស្ថិតនៅត្រើយខាងលិចនៃប្រទេសក្រិច
- ឆ្នាំកសាង : ៤៤០មុន គ.ស
- កសាងដោយ : ស្ថាបត្យករក្រិចហ្វេឌីអាស
- វត្ថុបំណង : ឧទ្ទិសចំពោះ អាទិទេពហ្សេអ៊ូស
- បច្ចុប្បន្នវិនាសសាបសូន្យបាត់ហើយ ( ភ្លើងឆេះនៅឆ្នាំ៤៦២នៃ គ.ស)

តាមរយៈឯកសារដែលបានកត់ត្រាទុក ជាភាសាក្រិច ក៏ដូចជាភាសាឡាតាំង ស្តីអំពីអច្ឆរិយវត្ថុទាំង៧នៃយុគបុរាណ សុទ្ធសឹងតែបានរួមបញ្ចូលនូវចម្លាក់នៃទេវរូបហ្សេអ៊ូស នាទីក្រុងអូឡាំពា ដែលត្រូវបានស្ថាបនាឡើងដោយស្ថាបត្យករក្រិចមានឈ្មោះថាហ្វេឌី អាស(Pheidias) ប៉ុន្តែជាប្រការគួរឱ្យសោកស្តាយប្រសិនបើយើងធ្វើការប្រៀបធៀបវាទៅនឹងមហាពីរ៉ាមីត ឬមហាចេតិយម៉ូសូលូស ឬសូម្បីតែជាមួយនឹងប្រាសាទដាយអាណា នោះចម្លាក់ទេវរូបហ្សេអ៊ូស គឺបច្ចុប្បន្នបានវិនាសសាបសូន្យទាំងស្រុងបាត់ទៅហើយ អ្វីដែលនៅសល់មកដល់ពេលនេះ គឺមានត្រឹមតែឈ្មោះប៉ុណ្ណោះ.......។

វាមានទីតាំងស្ថិតនៅអតីតទីក្រុងអូឡាំពាបុរាណ (បច្ចុប្បន្នក្រិច) កន្លែងដែលជាទីចាប់កំណើតឡើងនៃកីឡាអូឡាំពិក (កីឡាដែលគេជឿថាត្រូវបានប្រារព្ធឡើងនៅក្នុងឆ្នាំ៧៧៦មុន គ.ស ដែលជាឆ្នាំចាប់ផ្តើមដំបូង នៃប្រតិទិនរបស់ក្រិច) ហើយត្រូវបានស្ថាបនាឡើង ក្នុងគោលបំនងដើម្បីសម្តែងការគោរពចំពោះអាទិទេពហ្សេអ៊ូស (អាទិទេពនៅក្នុងទេវកថាបុរាណរបស់ក្រិច) ។

"**ហ្វេឌីអាស**" (Pheidias)ជាឈ្មោះនៃស្ថាបនិក ដែលបានស្ថាបនានូវរូបចម្លាក់ហ្សេអ៊ូសដែលមានឈ្មោះល្បីកងរំពងនៅក្នុងលោក។ គាត់បានស្ថាបនានូវមហាបដិមានៃទេវធីតា អាថេណា (Athena) ដែលមានកម្ពស់១២ម៉ែត្រក្នុងប្រាសាទផាថេណុន ស្ថិតនៅក្នុងទីក្រុងអាថែន ព្រមទាំងបានធ្វើការងារ ជាជាងឆ្លាក់នៅផ្នែកខាងក្រៅនៃប្រាសាទដដែលនោះផងដែរ ។ហ្វេឌីអាសបានធ្វើដំណើរទៅកាន់អូឡាំពា បន្ទាប់ពីការងារនៅក្នុងក្រុងអាថែនរបស់គាត់ត្រូវបានបញ្ចប់ ក្នុងគោល


somano_khmer@yahoo.com



មើលឱ្យច្បាស់ទៅបាទ! ថាតើមហាទេវរូបដ៏ល្បីល្បាញនេះមានទំហំប៉ុណ្ណា

បំណងចាប់ផ្ដើមនូវការងារដែលក្រោយមកធ្វើឱ្យគាត់មានឈ្មោះល្បីល្បាញក្នុងទំព័រនៃប្រវត្តិសាស្ត្រក្រិចនោះ គឺការស្ថាបនានូវចម្លាក់ទេវរូបហ្សេអ៊ូស ។ ហ្វេឌីអាសចាប់ផ្ដើមការងាររបស់គាត់ក្នុងការស្ថាបនាទេវរូបហ្សេអ៊ូស ក្នុងអំឡុងឆ្នាំ៤៤០មុនគ្រិស្តសករាជ ។ គាត់បានធ្វើឱ្យមានវិវឌ្ឍនភាពនៃបច្ចេកទេសក្នុងការកសាងនូវមហាបដិមាដែលធ្វើអំពីមាស និងភ្លុកដំរី ។ រោងជាងដែលហ្វេឌីអាសប្រើ ក្នុងការស្ថាបនាទេវរូបហ្សេអ៊ូស បានបន្សល់ទុករហូតមកដល់បច្ចុប្បន្ន ហើយគឺទីនោះឯង ដែលគាត់បានប្រើសម្រាប់ជាទីដាប់ឆ្លាក់ នូវបំណែកផ្សេងៗនៃបដិមាករ មុនពេលដែលវាត្រូវបានផ្គុំឡើងនៅផ្នែកខាងក្នុងនៃប្រាសាទ ។ ពេលដែលបដិមាករត្រូវបានស្ថាបនារួចរាល់ វាស្ទើរតែពេញល្មមទៅនឹង ផ្នែកខាងក្នុងនៃប្រាសាទ ។

ស្រ្តាបូ (Strabo) ភូមិវិទូសញ្ជាតិក្រិច ធ្លាប់បានធ្វើការពិពណ៌នាទុកយ៉ាងដូច្នេះថា " ទោះបីថាប្រាសាទមានទំហំធំក៏ពិតមែន ប៉ុន្តែបដិមាករត្រូវបានស្ថាបនាឡើង ដោយមានទំហំស្ទើរតែសមាមាត្រទៅនឹងទំហំនៃប្រាសាទ។ បដិមាករត្រូវបានស្ថាបនា ក្នុងឥរិយាបថអង្គុយនៅលើបល្ល័ង្ក ដោយផ្នែកខាងលើបំផុត (សិរសា) ស្ទើរតែប៉ះទៅនឹងដំបូលប្រាសាទ។ តាមរយៈការអធិប្បាយខាងលើនេះ យើងអាចធ្វើការសន្និដ្ឋានបានថា ប្រសិនបើបដិមាហ្សេអ៊ូសអាចងើបឈរបានវិញនោះ គឺប្រាកដជាខ្ពស់ផុតដំបូលប្រាសាទទៅទៀត( ធ្លុះដំបូលប្រាសាទ) ។ អ្វីដែលស្រ្តាបូអះអាងគឺពិតជាត្រឹមត្រូវ ដោយមិនរួមបញ្ចូលទាំងសិល្បៈនៃការដាប់ឆ្លាក់ដែលត្រូវបានគេលើកសសើរជាទូទៅផងនោះ ទំហំរបស់វាគឺពិតជាគួរឱ្យកោតសសើរ ហើយដែលបានធ្វើឱ្យចម្លាក់ទេវរូបហ្សេអ៊ូសមានភាពអស្ចារ្យ ព្រមទាំងបានទាក់យកនូវមនោសញ្ចេតនារបស់ពួកអ្នកបុរាណវិទ្យា និងពួកកវីនិពន្ធទាំងឡាយឱ្យអត់ទ្រាំមិនសសើរមិនបាន។ ឋានផ្នែកខាងក្រោមនៃបដិមាករមានប្រវែងប្រហែល៦.៥ម៉ែត្រ និងកម្ពស់១ម៉ែត្រ រីឯតួទេវរូបវិញ គឺមានកម្ពស់១៣ម៉ែត្រ (ស្មើនឹងកម្ពស់នៃផ្ទះល្វែង៣ជាន់) ។ នេះអាចចាត់ទុកបានថា ជាកម្ពស់ដ៏ខ្ពស់ដែលធ្វើឱ្យអាគន្តុកៈ (អ្នកដែលបានទៅទស្សនា) ភាគច្រើននាំគ្នាអធិប្បាយ អំពីបល្ល័ង្កច្រើនជាងអធិប្បាយអំពីលក្ខណៈភិនភាគរបស់តួទេវរូប។

ជើងបល្ល័ង្កត្រូវបានប្រដាប់តុបតែងលំអរ ទៅដោយរូបចម្លាក់នរសិង្ហ (សំណាកដែលមានក្បាលជាមនុស្សឬជាសត្វផ្សេងៗ ប៉ុន្តែមានខ្លួនជាសត្វសិង្ហ) ហើយនិងចម្លាក់នៃទេវធីតាវិកធើរៀ( អាទិទេពនៃជ័យជំនះ) ព្រមទាំងចម្លាក់នៃអាទិទេព

ជាច្រើនផ្សេងទៀត នៅក្នុងទេវកថាក្រិចដូចជា **អាប៉ូឡូ** (Apollo) **អាថេ មីស** (Artemis) ហើយនិងបុត្រាបុត្រីរបស់អាទិទេព **នីអូបេ** (Niobe's children) ជាដើម ។

នៅសតវត្សន៍ទី២នៃគ.ស លោកក្រិកផូ **សានាស** (The Greek Pausanias)បានរៀបរាប់អំពីចម្លាក់ទេវរូបហ្សេអ៊ូស ដូចតទៅនេះថា "សិរសារបស់ទេវរូបត្រូវបានឆ្លាក់ព័ទ្ធជុំវិញ ទៅដោយរូបនៃកំរងផ្កាអូលីវ( ប្រៀបដូចមកុដ) ដៃខាងស្តាំរបស់ទេវរូបកាន់នូវរូបទេពធីតាវិកធើរៀ ដែលធ្វើអំពីភ្លុកហើយនិងមាស ប្រដាប់ដោយត្បូងពេជ្រជាច្រើនគ្រាប់ រីឯក្នុងដៃខាងឆ្វេងវិញកាន់នូវដំបងរាជ្យ ដែលធ្វើពីលោហធាតុដ៏ប្រណីតគ្រប់ប្រភេទ និងដាំដោយត្បូងពេជ្រជាច្រើនគ្រាប់ ដែលមានតម្លៃមិនអាចកាត់ថ្លៃបាន ហើយមានរូបសត្វឥន្ទ្រីយ៍នៅពីលើ ។ ស្បែកជើងរបស់ទេវរូប ត្រូវបានធ្វើឡើងអំពីមាស ដូចគ្នាទៅនឹងអាវផាយ ដែលបំពាក់ពីលើទេវរូប ។ សម្លៀកបំពាក់ត្រូវបានឆ្លាក់លំអរ ដោយរូបសត្វផ្សេងៗ ជាមួយនិងរូបផ្កាលីលី ។ តួបល្ល័ង្កត្រូវបានប្រដាប់តាក់តែងដោយមាស ត្បូងពេជ្រ ឈើខ្មៅ និងភ្លុក ។

ចម្លាក់ទេវរូបនេះ ពេលខ្លះក៏ត្រូវបានប្រដាប់តាក់តែង ដោយវត្ថុមានតម្លៃផ្សេងៗបន្ថែមទៀតពីសំណាក់ព្រះរាជា និងអ្នកគ្រប់គ្រងរដ្ឋទាំងឡាយ ប៉ុន្តែអ្វីដែលគួរឱ្យកត់សំគាល់បំផុត ក្នុងចំណោមវត្ថុដ៏មានតម្លៃទាំងនោះគឺ វាំងននដែលធ្វើអំពីខ្សែ្លន សំអិតសំអាងដោយគំនូរ ដែលត្បាញដោយជនជាតិអាល់ហ្សេរី ហើយដែលត្រូវបានឧទ្ទិសសម្រាប់ជា ការគោរពបូជាចំពោះអទិទេពហ្សេអ៊ូស ដោយព្រះចៅអាន់ថ្យូ ឆាស់ទី៤ នៃប្រទេសស៊ីរ ។


somano khmer yahoo.com

ទេវរូបហ្សេអ៊ូសនេះត្រូវបានគេតម្កល់ទុក ក្នុងប្រាសាទដ៏ល្អឆើតឆាយ ជាប្រាសាទដែលមានរចនាបថបែបសាមញ្ញ (ហើយដែលក្រោយមកការកែប្រែជាច្រើនបានត្រូវធ្វើឡើង) ដែលគូរប្លង់ និងស្ថាបនាដោយវិស្វករ**លីបុន** (Libon) និងកសាងឡើងនៅក្នុងឆ្នាំ៤៥០មុនគ.ស (១០ឆ្នាំមុនការកសាងចម្លាក់ទេវរូប) ក្នុងយុគសម័យ ដែលអាណាចក្រក្រិចបុរាណ មានការរីកចម្រើនលូតលាស់ដល់កម្រិតកំពូល ហើយស្ថាបត្យករហ្វេឌីអាសជាមនុស្ស ដែលទទួលនូវភារៈដ៏សំខាន់ ក្នុងការស្ថាបនានូវមហាបដិមាហ្សេអ៊ូស ដែលគេចាត់ទុកដូចជាវត្ថុដ៏សក្តិសិទ្ធ សម្រាប់តម្កល់ទុកនៅក្នុងប្រាសាទនេះ។




**គំនូរដែលបង្ហាញពីប្រាសាទហ្សេអ៊ូសទីតម្កល់នូវមហាទេវរូបហ្សេអ៊ូស**




គំនូរទេវរូបហ្សេអ៊ីសគូរដោយ វិធីព្រករសម័យថ្មីបំពាក់ទៅ ដោយសំពត់ខ្សែដីស្រស់ស្អាត

អស់រយៈពេលជាច្រើនឆ្នាំ ដែលចម្លាក់ទេវរូបហ្សេអ៊ីស បានទាក់ទាញនូវអ្នកទេសចរ និងអ្នកធម្មយាត្រាពីជុំវិញពិភពលោក ។ នៅក្នុងសតវត្សន៍ទី២មុនគ.ស មានការជួសជុលកែប្រែ ដែលប្រកបដោយបច្ចេកទេសខ្ពស់ជាច្រើន ត្រូវបានគេធ្វើឡើង ទៅលើចម្លាក់ទេវរូបដែលមានវ័យចំណាស់ ។

ក្នុងសតវត្សន៍ទី១នៃគ.ស ព្រះចៅចក្រពត្តិរ៉ូម៉ាំង **ខាលី គូឡា** (Caligula) ទ្រង់មានព្រះបំណង ដឹកជញ្ជូនយកនូវទេវរូបហ្សេអ៊ីស ទៅកាន់ទីក្រុងរ៉ូមរបស់ព្រះអង្គ ប៉ុន្តែការប៉ុនប៉ងរបស់ព្រះអង្គត្រូវបានបរាជ័យទៅវិញ នៅពេលរន្ទាដែលធ្វើឡើងដោយមនុស្សរបស់ទ្រង់ បានរលំបាក់ធ្លាក់ចុះមក ។

៣សតវត្សន៍បន្ទាប់មកទៀត ក្រោយពីកីឡាអូឡាំពិកត្រូវបានហាមឃាត់

នៅឆ្នាំ៣៩១នៃគ.ស ដោយព្រះចៅចក្រពត្តិធេអូ ដូស្សៀស(Theodosius) ទី១ ទ្រង់ជាព្រះរាជាដែលមិនមានជំនឿ ទៅលើលទ្ធិសាសនាពីបុរមបុរាណ ព្រះវិហារហ្សេអ៊ូសត្រូវបានបញ្ជារឱ្យបិទទ្វារទាំងស្រុង។ មួយសតវត្សន៏ក្រោយមកទៀត ទីក្រុងអូឡាំពាបុរាណត្រូវបានបំផ្លាញ ដោយគ្រោះរញ្ជួយដី ការបាក់ដី ព្រមទាំងទឹកជំនន់ ចំណែកឯទេវរូបហ្សេអ៊ូសវិញ ដំបូងឡើយត្រូវជនជាតិក្រិច ដឹកជញ្ជូនយកទៅទុកនៅឯព្រះរាជវាំង ខនស្តេនធី ណូផល (Constantinople) ជាទីដែលចម្លាក់ទេវរូបនេះតាំងនៅ រហូតដល់ពេលដែលវាត្រូវបានបំផ្លាញ ដោយអគ្គីភ័យដ៏ធំមួយ បូករួមជាមួយនឹងគ្រោះរញ្ជួយដីដ៏ខ្លាំង នៅក្នុងឆ្នាំ៤៦២នៃគ.ស។




**នេះឯងប្រាសាទដែលអតីតធ្លាប់ជាទីតម្កល់ទុវមហាទេវរូបហ្សេអ៊ូស**

បើទោះណាជាមានឯកសារជាច្រើន ដែលសរសេរដោយប្រវត្តិវិទូសម័យបុរាណអះអាងថា មានការចម្លងនូវស្ថាបត្យកម្មនៃទេវរូបហ្សេអ៊ូសជាច្រើន ត្រូវបានគេធ្វើឡើង ដោយរួមបញ្ចូលទាំងគំរូដើមដ៏ធំ (ការចម្លងដំបូងបំផុត) នៅឯស៊ីរ៉ិន (Cyrene) ក្តី ក៏គេនៅតែមិនឃើញមានសូម្បីតែមួយ ក្នុងចំណោមស្ថាបត្យកម្មទាំងនោះ ដែលបានបន្សល់ទុករហូតមកដល់បច្ចុប្បន្ន។ ក្នុងចំណោមស្ថាបត្យកម្មចម្លងដ៏ច្រើនទាំងនោះ មានដូចជាស្ថាបត្យកម្មចម្លងរបស់រ៉ុន អេឡាច់ បច្ចុប្បន្នត្រូវបានគេជឿថា វាហាក់ដូចជាមិនមានការពិតទាល់តែសោះ ប៉ុន្តែអ្វីដែលគេនៅតែមានចម្ងល់ ហើយចង់ស្វែងរកចម្លើយដ៏ពិតប្រាកដ នោះគឺវាទាក់ទងតែជាមួយនឹងលក្ខណៈពិតប្រាកដ នៃមហាបដិមាករហ្សេអ៊ូស ព្រមទាំងសិល្បៈនៃការដាប់ឆ្លាក់ដ៏អស្ចារ្យរបស់ក្រិចបុំណ្ណោះ។

ព័ស្តុតាងដ៏ល្អបំផុត ដែលយើងអាចរកឃើញបាន ដើម្បីបញ្ជាក់ពីលក្ខណៈរូបរាងរបស់ទេវរូបហ្សេអ៊ូស គឺកាក់សិរិទ្ធ **អេលីស** (Elis) ក្នុងយុគសម័យហាដ្រៀន (Hadrian) ដែលបច្ចុប្បន្នមានតែនៅក្នុងទីក្រុង **ផ្លរ៉ែន** (Florence) នៃប្រទេសអ៊ីតាលីតែមួយគត់។ វាគឺជាកាក់សិរិទ្ធដែលគេធ្វើឡើង ដោយចម្លងតាមរូបដើមទាំងស្រុង នៃមហាបដិមាហ្សេអ៊ូស ហើយមានបណ្តោយប្រហែល២សង់ទីម៉ែត្រ។

បាទ! គឺអាស្រ័យដោយកាក់សិរិទ្ធនេះឯងហើយ ដែលអាចឱ្យមនុស្សជំនាន់ថ្មី បានដឹងពីលក្ខណៈទ្រង់ទ្រាយពិតប្រាកដ របស់ចម្លាក់ទេវរូបដ៏ល្បីល្បាញបំផុតនៅលើលោក ហើយរូបស្អាត១នៃចម្លាក់ទេវរូប នៅក្នុងសៀវភៅដែលលោកអ្នកកំពុងអាននេះ ក៏សុទ្ធតែបានមកពីការគូររបស់វិចិត្រករសម័យបច្ចុប្បន្ន ដោយយោង

**នេះឯងហើយកាក់សិរីទ្ធអេលីស មានឆ្លាក់រូបទេវរូបហ្សេអ៊ូសដែល អាចជួយឱ្យគេបានដឹងអំពីលក្ខណៈ ទ្រង់ទ្រាយនៃចម្លាក់ទេវរូបដែលបាន វិនាសសាបសូន្យបាត់ទៅនោះ**



ទៅតាមរូប ដែលមាននៅលើកាក់នោះឯង ។

បច្ចុប្បន្ននេះមិនមានអ្វីបន្សល់ទុក នៅឯទីតាំងនៃអតីតប្រាសាទ ដែលជាទីតម្កល់នូវទេវរូបហ្សេអ៊ូស ក្រៅពីដុំថ្មជាច្រើនជាមួយខឿនសំណង់ ព្រមទាំងសសរដែលរលំបាក់ធ្លាក់ចុះមកប៉ុណ្ណោះ ។



- ឈ្មោះ : ប្រាសាទអាធេមីស ឬប្រាសាទដាយអាណា
- ទីតាំង : នាតំបន់អេហ្វេស៊ុស ស្ថិតនៅត្រើយខាងលិចនៃប្រទេសទួរគី
- ឆ្នាំកសាង : ៥៥០មុនគ.ស
- កសាងដោយ : អ្នកនគរក្រិចបុរាណ
- វត្ថុបំណង : ជាអនុស្សាវរីយ៍ដល់ទេវធីតាអាធេមីស

-បច្ចុប្បន្នបន្សល់នៅត្រឹមខឿនបាក់បែក ជាមួយនិងសសរស្តម្ភមួយចំនួនប៉ុណ្ណោះ( ត្រូវបំផ្លាញដោយពួកជនជាតិហ្គូសក្នុងចម្បាំង នៅឆ្នាំ២៦២នៃ គ.ស)

"ក្លាមពេលដែលខ្ញុំបានមកឃើញនូវមហាប្រាសាទដ៏ធំស្កឹមស្កៃនេះ ជាលើកដំបូង វាធ្វើឱ្យខ្ញុំមានអារម្មណ៍ថា វាមិនគ្រាន់តែជាប្រាសាទធម្មតាប៉ុណ្ណោះទេ ប៉ុន្តែវាគឺពិតជាស្ថាបត្យកម្មដ៏ល្អជាងគេបំផុត នៅលើភពផែនដី បើប្រៀបធៀបទៅនឹងអច្ឆរិយវត្ថុ៦ផ្សេងទៀត " នេះជាបទបរិយាយ ដែលសរសេរដោយអ្នកទេសចរសម័យបុរាណ ដែលបានទៅទស្សនាផ្ទាល់នឹងភ្នែក នូវមហាប្រាសាទដ៏អស្ចារ្យមួយនេះ ។

វាមានទីតាំងស្ថិតនៅទីក្រុងបុរាណ **អេហ្វេ ស៊ុស** (Ephesus) ជិតទីក្រុងសេលគុក (Selcuk) បច្ចុប្បន្នចម្ងាយប្រហែល ៥០គ.ម ភាគខាងត្បូងនៃអ៊ីសមៀ (Izmir) ក្នុងប្រទេសទួរគី ។

សាសនស្ថានដំបូងបំផុត ដែលត្រូវបានគេធ្វើឡើង ក្នុងអំឡុងឆ្នាំ៨០០នៃ គ.ស នៅលើវាលល្បាប់ជិតទន្លេ នាទីក្រុងអេហ្វេស៊ុស (ក្រោយមកជាទីតាំងនៃមហាប្រាសាទដាយអាណា) សម្រាប់ជាការឧទ្ទិសទៅដល់ទេវធីតាអាធេមីស គឺវាមានរូបរាងត្រឹមតែជាខ្ទម ដែលធ្វើឡើងដោយសសរឈើ២ ដែលគេដាក់បញ្ឈរដោយមានសសរឈើមួយដើមទៀត ដាក់ផ្តេកនៅពីខាងលើ និងមានដាក់តាំងរូបបដិមានៃទេពធីតាអាធេមីស នៅចំកណ្តាលនៃសសរឈើទាំង២នោះប៉ុណ្ណោះ (ជាសម័យដែលមិនទាន់សូវមានការរីកចម្រើន) ។

សូមបញ្ជាក់ថា ទេពធីតា**អាធេ មីស** នៃទីក្រុងអេហ្វេស៊ុស (ពេលខ្លះត្រូវបានគេហៅដោយឈ្មោះម្យ៉ាងទៀតថា ដាយអាណា) គឺមានលក្ខណៈខុសគ្នាទៅនឹងទេពធីតាអាធេមីស ដែលត្រូវបានគេគោរពបូជា នៅក្នុងប្រទេសក្រិច ។

ទេពីអាធេមីសរបស់ក្រិច គឺជាអាទិទេពនៃការបរបាញ់ ក្នុងខណៈដែលទេពីអាធេមីសនៃអេភេសុស គឺជាអាទិទេពនៃភាពសម្បូររុងរឿង ហើយដែលជានិច្ចជាកាល ព្រះនាងត្រូវបានគេគូររូប ក្នុងឈុតសម្លៀកបំពាក់ ដែលប្រដាប់ពេញទៅដោយស៊ុតផ្សេងៗ ឬសុដន់ជាច្រើន( ទឹកដោះតំណាងឱ្យភាពសម្បូររុងរឿងឥតខ្វះខាត) ឬមួយក៏ជានិមិត្តសញ្ញាផ្សេងៗដ៏ទៃទៀត ដែលតំណាងឱ្យភាពសម្បូរសប្បាយ ចាប់តាំងពីចង្កេះរហូតទៅដល់ស្មារបស់អង្គទេពី។




បដិមាដាយអាណាដែលត្រូវគេឆ្លាក់ប្រកបទៅដោយសុដន់ជាច្រើនដែលតំណាងឱ្យភាពសម្បូររុងរឿង

តាមជំនឿរបស់ជនជាតិក្រិចបុរាណ ប្រាសាទដាយអាណាដំបូងបំផុត មានតម្កល់នូវថ្មសក្តិសិទ្ធ( ប្រហែលជាអាចម៏ផ្កាយ) ដែលជាអំណោយប្រទានដោយជូពីទើរ ( ឈ្មោះម្យ៉ាងទៀតរបស់អាទិទេពហ្សេអ៊ុស ដែលយើងទើបបានពោលដល់នៅក្នុងអច្ឆរិយវត្ថុទី៣)។ ប្រាសាទនេះត្រូវបានបំផ្លាញ ហើយនិងស្ថាបនាឡើងវិញជាច្រើនលើកច្រើនសា ក្នុងអំឡុងរយៈពេលត្រឹម ៣-៤សតវត្សន៍ ប៉ុណ្ណោះ។




**ប្រាសាទដាយអាណាមើលចំពីមុខ**

ក្នុងឆ្នាំ៦០០មុនគ.ស ទីក្រុងអេហ្វេស៊ុសបុរាណបានក្លាយទៅជាទីក្រុងកំពង់ផែពាណិជ្ជកម្ម ដ៏សំខាន់នៅក្នុងតំបន់ ហើយគឺពេលនោះឯងដែលស្ថាបត្យករ **ឈើ ស៊ីប្រ៊ុន** (Chersiphron) ត្រូវបានគេជួលឱ្យមកស្ថាបនានូវមហាប្រាសាទដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញលើផែនប្រថពីនេះ។ គាត់បានស្ថាបនាវាឡើងជាមួយនឹងសសរថ្ម ដែលមានទំហំធំហើយខ្ពស់ៗជាច្រើន (មិត្តអ្នកអានសាកគិតទៅមើលថា យានដែលផ្ទុកនូវសសរថ្មទាំងនោះ ប្រហែលជាត្រូវលិចផុងទៅក្នុងវាលល្បាប់ ដែលនៅព័ទ្ធជុំវិញបរិវេណប្រាសាទនោះផងក៏មិនដឹង)។ អាស្រ័យដោយទេពកោសល្យ និងភាពឆ្លាតវាងវៃ ឈើ ស៊ីប្រ៊ុនបានដាក់សសរទាំងនោះឱ្យផ្តេក

បណ្តោយ ហើយបន្ទាប់មកទើបគាត់ធ្វើឱ្យវាររមៀល រហូតទៅដល់កន្លែងដែលត្រូវសាងសង់។

ប្រាសាទដាយអាណាដំបូងនេះ គឺមិនបានស្ថិតស្ថេរនៅយូរប៉ុន្មានឡើយ។ ក្នុងឆ្នាំ៥៥០មុនគ.ស ព្រះចៅ**ក្រូអេស៊ុស** (Croesus) នៃនគរលីឌា (Lydia) បានវាយដណ្តើមកាន់កាប់រាជធានីអេហ្វេស៊ុស និងរាជធានីឯទៀត១ ក្នុងអាណាចក្រក្រិចបុរាណ ហើយដែលបានធ្វើឱ្យប្រាសាទដ៏ល្អឯកមួយនេះ ត្រូវបានបំផ្លាញនៅក្នុងអំឡុង នៃការប្រយុទ្ធតស៊ូគ្នា។ ជាភ័ព្វសំណាង ព្រះចៅក្រូអេស៊ុស ទ្រង់បានបង្ហាញឱ្យឃើញថា ព្រះអង្គគឺជាអ្នកឈ្នះដែលប្រកបទៅដោយទឹកចិត្តមេត្តា តាមរយៈការធ្វើវិភាគទាន ដោយព្រះទ័យសប្បុរស ដើម្បីស្ថាបនានូវមហាប្រាសាទដាយអាណាថ្មីមួយផ្សេងទៀត។ ប្រាសាទថ្មីនេះ គឺត្រូវបានគេស្ថាបនាឡើង ឱ្យមានរូបរាងតូចជាងប្រាសាទចាស់ ហើយមានទីតាំងស្ថិតនៅទល់មុខ នឹងប្រាសាទចាស់ដែលត្រូវបំផ្លាញដោយសង្គ្រាម។ មិនមែនជាឈើស៊ីប្រ៉ុន ដែលជាស្ថាបត្យករស្ថាបនានូវមហាប្រាសាទចាស់នោះឡើយ ប៉ុន្តែគាត់គឺជាស្ថាបត្យករ ដែលមានឈ្មោះថា **ធេអូដូរ៉ាស់**(Theodorus)។ ប្រាសាទដែលធេអូ ដូរ៉ាស់កសាងក្រោយនេះ មានបណ្តោយប្រហែល៩២ម៉ែត្រ និងទទឹង៤៦ម៉ែត្រ ស្ថិតលើបរិវេណដែលមានទំហំធំជាងតួប្រាសាទ៤ដង។ ដំបូលដ៏ធំនៃប្រាសាទ ត្រូវបានទ្រដោយសសរថ្មកែវជាង១០០ដើម ។ ប្រាសាទដាយអាណាថ្មី ដែលជាមោទនភាពរបស់អ្នកស្រុកអេហ្វេស៊ុសនេះ តាំងនៅរហូតមកដល់ឆ្នាំ៣៥៦មុនគ.ស( ជិត២០០ឆ្នាំ) ក៏ត្រូវជួបប្រទះនូវមហន្តរាយជាថ្មីម្តងទៀត ក្រោមថ្វីដៃរបស់បុរសដែលមានឈ្មោះថាហេរ៉ូ **ស្ត្រាទុស** (Herostratus)



ស្គាល់ទេបាទ? នេះឯងហើយក្បាច់ចម្លាក់នៅលើសសរស្ដម្ភនៃមហាប្រាសាទដាយអាណា

តាមរយៈការចង់ឱ្យខ្លួនឯងមានឈ្មោះល្បី នៅក្នុងទំព័រប្រវត្តិសាស្ត្រ ហេរ៉ូស្ត្រាទុស ដែលគេស្គាល់ថាជាយុវជនមានដើមកំណើត នៅនាទីក្រុងអេហ្វេស៊ុស បានរៀបចំផែនការដើម្បីដុតបំផ្លាញនូវមហាប្រាសាទ ដ៏ល្អឯកមួយនេះឱ្យឆេះវិនាសខ្ទេចខ្ទី។ ទីបំផុតគំនិតចង់ល្បី ដោយប្រើវិធីឆ្កួតៗរបស់គាត់ ពិតជាបានសម្រេចមែន ដោយឈ្មោះរបស់គាត់ត្រូវបានប្រវត្តិសាស្ត្រចារឹកទុក រៀងដរាបមកដល់បច្ចុប្បន្ន (ថាជាមនុស្សចង្រៃបំផុតនៅក្នុងលោក) បើទុកណាជាប្រជាពលរដ្ឋអេហ្វេស៊ុសនាំគ្នាខឹងសម្បារយ៉ាងខ្លាំង ហើយបង្កើតច្បាប់ហាមមិនឱ្យនណារំលឹក ឬដាក់ឈ្មោះបុត្រធីតារបស់ខ្លួនថាហេរ៉ូ ស្ត្រាទុស (មិនចង់ឱ្យគាត់មានឈ្មោះល្បីនៅក្នុងប្រវត្តិសាស្ត្រ) ដោយសង្កត់ធ្ងន់ថា ជនណាក៏ដោយដែលបំពារបំពានទៅលើច្បាប់នេះ នឹង

ត្រូវមានទោស ដល់ថ្នាក់ប្រហារជីវិតយ៉ាងណាក៏ដោយចុះ ។

មិនយូរប៉ុន្មានបន្ទាប់អំពីការបំផ្លាញនេះ ប្រាសាទថ្មីមួយផ្សេងទៀតក៏ត្រូវបានគេស្ថាបនាឡើង ។ ស្ថាបនិកដែលគេជ្រើសរើស សម្រាប់ការសាងសង់នូវមហាប្រាសាទដាយអាណាទីពនេះ មានឈ្មោះថា**ស្កូផាស** (Scopas) ។ អាចចាត់ទុកបានថា នេះគឺជាស្ថាបនកម្មដ៏ល្អបំផុត នៅក្នុងជីវិតជាស្ថាបនិករបស់គាត់ ។ ក្នុងយុគសម័យនោះទីក្រុងអេហ្វេស៊ុសគឺជា ទីក្រុងសេដ្ឋកិច្ចដ៏សំខាន់បំផុតមួយ នៅក្នុងតំបន់ ហេតុដូច្នេះទើបបានជាគេសង្កេតឃើញថា មិនមានការខ្វះខាតនូវថវិកា សម្រាប់ការសាងសង់ ( ថវិកាក្នុងការសាងសង់ គឺមានចំនួនច្រើនលើសលប់) នោះឡើយ ។

យោងទៅតាមកំណត់ត្រារបស់លោក **ភ្លីនី** (Pliny) ប្រវត្តិវិទូសញ្ជាតិរ៉ូម៉ាំងបានធ្វើការពណ៌នានូវមហាប្រាសាទដាយអាណាថាជា " មហាប្រាសាទដ៏ស្រស់ស្អាតបំផុតរបស់ក្រិច ហើយដែលធ្វើឱ្យអ្នកដែលបានមកទស្សនា អត់ទ្រាំមិនសរសើរមិនបាន " ។

មហាប្រាសាទថ្មី ( ប្រាសាទទី៣) ត្រូវបានសាងឡើងនៅលើវាលល្បាប់ដែលជាទីតាំងដើម នៃមហាប្រាសាទដាយអាណាដំបូង ។ ក្នុងការរៀបចំនូវផ្ទៃដីសម្រាប់សាងសង់ទៀតសោត លោកភ្លីនីបានសរសេរទុកយ៉ាងដូច្នេះថា "ធ្យូងជាច្រើនត្រូវបានដាក់ពង្រាយនៅផ្នែកខាងក្រោម គ្របដណ្តប់ដោយរោមចៀម នៅផ្នែកខាងលើ " ។ វាគឺជាប្រាសាទដំបូង ដែលត្រូវបានគេស្ថាបនាឡើង ដោយប្រើថ្មកែវ ហើយលក្ខណៈវិសេសបំផុត គឺនៅត្រង់សសរថ្មកែវ៣៦ដើមដែលពោរពេញទៅដោយក្បាច់ចម្លាក់យ៉ាងល្អវិចិត្រ ។ នៅផ្នែកខាងក្នុងនៃប្រាសាទនេះ មានតម្កល់នូវ

ស្នាដៃនៃសិល្បៈកម្មជាច្រើន ដែលរួមបញ្ចូលទាំងរូបចម្លាក់មេទ័ពស្រីទាំង៤ ដែលធ្វើអំពីសំរិទ្ធផងដែរ ។



**នេះឯងហើយជាក្បាច់ចម្លាក់យ៉ាងល្អវិចិត្រនៅលើជើងទម្រនៃសសរស្តម្ភដែលទ្រទ្រង់តួប្រាសាទទាំងមូល**

នៅពេលដែល**អាឡិចសាន់ឌឺរ៍ មហារាជា** (Alexander the Great) ស្តេចយាងទៅកាន់អេភ្វេស៊ុស ក្នុងឆ្នាំ៣៣៣មុនគ.ស សំណង់ប្រាសាទទាំងមូល កំពុងស្ថិតនៅក្នុងអំឡុងនៃការសាងសង់ ។ ព្រះអង្គទ្រង់បានធ្វើព្រះរាជសំណើរសុំឧបត្ថម្ភនូវការសាងសង់រហូតបញ្ចប់ជាស្ថាពរ ប្រសិនបើអ្នកនគរអេភ្វេស៊ុស ព្រមចារឹកព្រះនាមរបស់ព្រះអង្គ នៅលើមហាប្រាសាទនោះថា " មហាប្រាសាទនេះត្រូវបានសាងថ្វាយ ដោយអាឡិចសាន់ឌឺរ៍ មហារាជនៃម៉ាសិដូនៀ "។ អ្នកស្រុកអេភ្វេស៊ុស

ទាំងឡាយ មិនចង់ឱ្យមានឈ្មោះរបស់អាឡិច សាន់ឌឺរ ឆ្លាក់ជាប់នៅលើប្រាសាទ ប៉ុន្តែក៏មិនហ៊ានប្រាប់ព្រះអង្គ ទៅតាមសេចក្តីពិតនោះដែរ ទើបទីបំផុតពួកគេសំរេចចិត្តឆ្លើយតប ដោយពាក្យពេចន៍បដិសេធយ៉ាងទន់ភ្លន់បំផុតថា " ជាការមិនសមគួរឡើយ ដែលអាទិទេពដូចជាព្រះអង្គ នឹងកសាងនូវប្រាសាទសម្រាប់ឧទ្ទិសដល់អាទិទេពអង្គដ៏ទៃ " ( គឺលើកសរសើរអាឡិចសាន់ឌឺរថាជាអាទិទេព ព្រមជាមួយនិងការបដិសេធទៅព្រមៗគ្នាក្នុងពេលតែមួយ) ហើយដែលព្រោះបិយវាចានេះឯងទើបធ្វើឱ្យទ្រង់មិនបានចាប់ទោស អ្វូសដំណើរអ្វីឡើយ ។

ផ្អែកលើកំណត់ត្រារបស់លោកភ្លីនីដដែល បានឱ្យដឹងថាមហាប្រាសាទដាយអាណាថ្មីនេះ មានបណ្តោយប្រវែង១៣០ម៉ែត្រ និងទទឹង៦៩ម៉ែត្រ ប្រកបទៅដោយសសរថ្មកែវចំនួន១២៧ដើម ហើយដែលមួយដើមៗមានកម្ពស់ប្រហែល ១៨ ម៉ែត្រ( ស្មើនឹងអគារ៤ជាន់) ។ ប៉ុន្តែបើយើងមើលទៅលើកំណត់ត្រាមួយផ្សេងទៀតរបស់លោក **ប៉ារតេ ណុន** (Parthenon) អះអាងដោយផ្អែកទៅលើគ្រោងសំណង់ដែលបន្សល់ទុកមកនៅក្នុងទីក្រុងអាថែន រហូតមកដល់បច្ចុប្បន្ន គឺវាមានបណ្តោយប្រវែងត្រឹមតែ៧០ម៉ែត្រ និងទទឹង៣០ម៉ែត្រ ប្រកបដោយសសរថ្មកែវចំនួន៥៨ដើមប៉ុណ្ណោះ ។

ស្តីអំពីរយៈពេលនៃការកសាងទៀតសោត លោកភ្លីនីបានអះអាងថា សំណង់ទាំងមូលត្រូវប្រើរយៈពេល១២០ឆ្នាំ ក្នុងការសាងសង់ ក្នុងខណៈដែលអ្នកជំនាញការខ្លះយល់ថា វាប្រហែលត្រូវប្រើពេលវេលា ត្រឹមពាក់កណ្តាលនៃពេលវេលា ដែលលោកភ្លីនីបានអះអាងប៉ុណ្ណោះ ។

អស់រយៈពេលជាង២សតវត្សន៍បន្ទាប់មកទៀត ដែលទីក្រុងអេភេស៊ុស នៅតែបន្តរីកចម្រើនឥតឈប់ឈរ ហើយក៏ជាគោលដៅមួយសម្រាប់អ្នកធម្មយាត្រាទាំងឡាយ ក្នុងការធ្វើដំណើរមកដើម្បីធ្វើនូវសក្ការៈបូជា ចំពោះអង្គទេពីនៅនាមហាប្រាសាទដ៏ធំស្កឹមស្កៃរបស់ព្រះនាង។ អាស្រ័យដោយចំនួនអ្នកទេសចរពីមួយថ្ងៃទៅមួយថ្ងៃ កាន់តែមានការកើនឡើងឥតឈប់ឈរ ទើបធ្វើឱ្យអ្នកស្រុកអេភេស៊ុសមួយចំនួន បែកគំនិតគិតរចនានូវរូបវត្ថុអនុស្សាវរីយ៍ផ្សេងៗ មានដូចជារូបទេពធីតា ដាយអាណា ជាដើម សម្រាប់ទុកលក់ឱ្យភ្ញៀវទេសចរ ដែលធ្វើដំណើរមកពីស្រុកឆ្ងាយ (អ្នកនៅក្នុងស្រុកចង់ទិញក៏បានគ្មានច្បាប់ហាមឃាត់ទេបាទ)។ មុខជំនួញនេះហាក់ដូចជា កាក់កបខ្លាំងណាស់ដែរ ហើយដែលក្រោយមកចំនួនអាជីវករចេះតែមានការកើនឡើង រហូតធ្វើឱ្យមហាវិថីផល ដែលស្ថិតនៅក្នុងទីក្រុងអេភេស៊ុសនាសម័យនោះ ណែនណាន់តាន់តាប់ទៅដោយហ្វូងអ្នកទេសចរ និងអាជីវករ ដែលពេលខ្លះរហូតដល់ថ្នាក់ធ្វើឱ្យកកស្ទះក៏មាន នេះបើយោងតាមកំណត់ហេតុដែលសរសេរដោយលោក **ដេមេទ្រាស** (Demitrius) ក្នុងដំណើរទៅកាន់ទីក្រុងនេះ នៅឆ្នាំ៥៧នៃ គ.ស។

បន្ទាប់ពីស្ថិតស្ថេរគង់វង្សនៅ អស់រយៈពេលជាង៥សតវត្សន៍រួចមក ទីបំផុតប្រាសាទដាយអាណាទី៣នេះ ក៏ត្រូវដល់នូវទីអវសានដូចជាប្រាសាទមុនៗដែរ ក្រោមការលុកលុយរបស់ពួក **ហ្គូស** (Goths) នៅក្នុងឆ្នាំ២៦២នៃគ្រឹស្តសករាជ ។ មួយសតវត្សន៍ក្រោយមកទៀត ទាំងទីក្រុងបុរាណអេភេស៊ុស ក៏ដូចជាមហាវិហារដាយអាណា ត្រូវធ្លាក់ទៅក្នុងសភាពទ្រុឌទ្រោមជាលំដាប់។



ផ្នែកខាងក្នុងនៃប្រាសាទដែលបន្សល់ទុកនៅត្រឹមខឿន ជាមួយនិងសសរបាក់បែកមួយចំនួនប៉ុណ្ណោះ

ក្នុងឆ្នាំ១៨៦៣ អាជ្ញាធរនៃសារៈមន្ទីរជាតិអង់គ្លេស បានសម្រេចបញ្ជូនស្ថាបត្យករចនធូរ៍ ធលវូត (John Turtle Wood) ទៅកាន់ប្រទេសទួរគីក្នុងគោលបំណងធ្វើការស្រាវជ្រាវរុករក នូវប្រាសាទដាយអាណា ដែលបានបាត់ដំណឹងសូន្យឈឹង អស់រយៈពេលរាប់រយឆ្នាំកន្លងមកហើយ ។ ក្នុងដំណើរស្វែងរករបស់គាត់លោកវូតបានជួបប្រទះនូវឧបសគ្គជាច្រើនមានជាអាទិ៍ បញ្ហាសន្តិសុខ ព្រោះថាតំបន់នោះ ជាតំបន់ដែលសម្បូរទៅដោយពពួកចោរ ហើយម្យ៉ាងទៀតក៏ពិបាកក្នុងការស្វែងរកកម្មករ (ដើម្បីធ្វើការជីករុករក) រីឯថវិកាក្នុងការរុករក ក៏មានកំណត់ប៉ុន្តែអ្វីដែលជាឧបសគ្គធំបំផុតសម្រាប់រូបគាត់នោះ គឺប្រហែលជាការកំណត់អំពីទីតាំងពិតប្រាកដរបស់មហាប្រាសាទថា ស្ថិតនៅឯណា ។




**គំនរបាក់បែកនៃមហាប្រាសាទដាយអាណាដែលបន្សល់ទុករហូតមកដល់បច្ចុប្បន្ន**

មួយឆ្នាំម្តង១អាជ្ញាធរនៃសារៈមន្ទីរអង់គ្លេស តែងតែគំរាមផ្តាច់ជំនួយថវិកាក្នុងការរុករក ប្រសិនបើលោកវូតមិនអាចរកឃើញស្លាកស្នាមណាមួយ នៃប្រាសាទដាយអាណាទេនោះ ប៉ុន្តែជារៀងរាល់ឆ្នាំ លោកវូតក៏នៅតែអង្វរករសុំឱ្យគេផ្តល់ជំនួយឱ្យលោក យ៉ាងហោចណាស់ត្រឹមមួយរដូវទៀត ។

" ព្យាយាមគង់បានសម្រេច " សុភាសិតខ្មែរមួយនេះពិតជាមិនខុសឡើយ ព្រោះថាបន្ទាប់ពីការប្រឹងប្រែងព្យាយាម អស់រយៈពេល៦ឆ្នាំ ទីបំផុតនៅក្នុងឆ្នាំ ១៨៦៩ លោកក៏បានរកឃើញនូវមហាប្រាសាទដាយអាណាដូចបំណង ដោយកម្មកររបស់គាត់បានជីកប៉ះទៅនឹងតួប្រាសាទដែលលិចកប់ នៅក្រោមវាលភក់ជំរៅ៦ម៉ែត្រ ។



**នេះឯងហើយទីតាំងនៃមហាប្រាសាទដែលគ្រាមួយធ្លាប់ជាប្រាសាទដ៏ស្រស់ស្អាតបំផុតនៅក្នុងលោក**

ក្នុងឆ្នាំ១៩០៤ ក្រុមការងារមួយដែលស្ថិតក្រោមការដឹកនាំផ្ទាល់ របស់លោកឌីជី **ហូហ្ក្រាស** (D.G Hograth) បានបន្តការជីករុករកទៅលើទីតាំងប្រាសាទដែលលោកវូតបានជីករកឃើញរួចមកហើយនោះ ដោយបានប្រទះឃើញនូវស្លាកស្នាមនៃមហាប្រាសាទចំនួន៥ ដែលប្រាសាទនិមួយៗ ត្រូវបានសង់ត្រួតនៅពីលើគ្នា.....!!។

បច្ចុប្បន្ននេះ ទីតាំងនៃមហាប្រាសាទដាយអាណា គឺជាវាលល្បាប់ដ៏ធំ។ សំណង់ប្រាសាទទាំងមូល មិនបានបន្សល់អ្វីទុកនៅ ក្រៅតែអំពីខឿនជាមួយនិងសសរបាក់បែកមួយចំនួន មើលទៅហាក់ចង់និយាយប្រាប់អ្នកទេសចរ ដែលបានទៅដល់ទីនោះថា "គ្រាមួយទីនេះធ្លាប់ជារាជធានីដ៏ល្បីល្បាញ ពោរពេញដោយមនុស្សកកកុញ និងជាទីតាំងនៃមហាប្រាសាទដ៏ស្រស់ស្អាតបំផុត ហើយដែលត្រូវបានគេរាប់បញ្ចូលថាជាវត្ថុដ៏អស្ចារ្យ មួយក្នុងចំណោមវត្ថុដ៏អស្ចារ្យទាំង៧ ដែលកសាងឡើងដោយស្នាដៃរបស់មនុស្ស"។




- ឈ្មោះ : មហាចេតិយម៉ូសូលៀម
- ទីតាំង : ស្ថិតនៅក្នុងទីក្រុងបតរ៉ាំ ប៉ែកនិរតីនៃប្រទេសទួរគី
- ឆ្នាំកសាង : ៣៥៣មុនគ.ស
- កសាងដោយ : ព្រះនាង អាធេមីសៀ
- វត្ថុបំណង : ជាទីតម្កល់ព្រះសពស្វាមីរបស់ព្រះនាង

-បច្ចុប្បន្នបន្សល់នូវត្រឹមគំនរថ្មបាក់បែកមួយចំនួនប៉ុណ្ណោះ( រងគ្រោះដោយរញ្ជួយដីនៅឆ្នាំ១៤០៤នៃគ.ស)

ដោយក្ដីអាឡោះអាល័យចំពោះព្រះភស្ដា ដែលជាទីស្រលាញ់ពេញចិត្ត ស្មើនឹងជីវិតរបស់ខ្លួន ដែលព្រះអង្គត្រូវមកអស់ព្រះជន្មទាំងនៅវ័យក្មេង និងដោយចង់ឱ្យព្រះអង្គទ្រង់ស្ថិតនៅក្នុងដួងចិត្ត របស់ព្រះនាងជាអមតៈ ទាំងចង់បង្ហាញឱ្យលោកទាំងមូល បានដឹងពីអំណាចនៃសេចក្ដីស្រលាញ់ ទើបព្រះនាងអាធេមីសៀ ទ្រង់បញ្ជារឱ្យសាងសង់ឡើង នូវមហាចេតិយដ៏ល្អឯក និងធំស្កឹមស្កៃបំផុត ហើយដែលក្រោយមកទៀត មានកេរ្តិ៍ឈ្មោះល្បីរន្ទឺពេញផែនពសុធាថាជា " **មហាចេតិយនៃក្ដីស្រលាញ់** " ។

**វា**ជាស្ថាបត្យកម្មដ៏ល្អឯកមួយ ដែលត្រូវបានគេចារឹកទុក នៅក្នុងប្រវត្តិសាស្ត្រ ដូចគ្នាទៅនឹងស្ថាបត្យកម្មដ៏ល្អឯកដ៏ទៃទៀត ខុសគ្នានៅត្រង់ថា វាមិនត្រូវបានគេសាងឡើង សម្រាប់ឧទ្ទិសដល់អាទិទេពរបស់ក្រិចបុរាណនោះទេ ប៉ុន្តែគឺមហាចេតិយដ៏ស្រស់ស្អាតមួយនេះ ត្រូវបានសាងឡើងសំរាប់ទុកជាទីតម្កល់នូវព្រះសពរបស់**ព្រះចៅម៉ូសូ លុស** (Mausolus) នៃអាណាចក្រពើសៀ (Persia) ព្រមទាំងព្រះរាជអគ្គមហេសីរបស់ព្រះអង្គគឺ**ព្រះនាង អាធេមីសៀ** (Artemisia) ។ វាត្រូវបានគូរប្លង់ និងស្ថាបនាដោយស្ថាបត្យករក្រិចលោក**សាតែរុស** និងលោក**ផៃ ធីអ៊ុស** (Satyrus and Pytheus) ហើយឆ្លាក់ដោយស្ថាបត្យករក្រិច៤នាក់ផ្សេងទៀតរួមមាន លោក **ស្កូផាស** ,**ប្រៃអាស៊ីស,** **ធិម៉ូធេអ៊ូស** និង **លីអូខារីស** (Scopas, Bryaxix, Timotheus, and Leochares) ។

មុននឹងចូលទៅដល់ការបរិយាយអំពី លក្ខណៈទ្រង់ទ្រាយនៃមហាចេតិយនេះ ខ្ញុំសូមនាំអារម្មណ៍មិត្តអ្នកអានទៅជួបជាមួយនឹង រឿងរ៉ាវមួយចំនួនទាក់ទង

ទៅនឹងប្រវត្តិនៃការសាងសង់ នូវមហាចេតិយដ៏អស្ចារ្យមួយនេះជាមុនសិន។

ក្នុងឆ្នាំ៣៧៧មុនគ.ស ទីក្រុង**ហាលី ខាណាស៊ុស**(Halicarnassus)គឺគ្រាន់តែជារាជធានីដ៏តូចមួយ ដែលស្ថិតនៅតាមបណ្ដោយឆ្នេរសមុទ្រមេឌីទែរ៉ានេប៉ុណ្ណោះ ។ ក្នុងឆ្នាំនោះឯងដែលព្រះចៅ**ហេខា ថំនើស** (Hecatomnus) នៃនគរមីឡាសា (Mylasa) ទ្រង់ចូលទិវង្គត់ ដោយបន្សល់ទុកព្រះបុត្រារបស់ព្រះអង្គឱ្យជាអ្នកស្នងរាជ្យបន្តពីព្រះអង្គ នោះគឺព្រះអង្គម្ចាស់ដែលមានព្រះនាមថា ម៉ូសូ លុស (The Mausolus) ។ ព្រះចៅម៉ូសូលុសបានទ្រង់បន្ត នូវកិច្ចការរបស់បិតាព្រះអង្គដោយទ្រង់ព្យាយាមពង្រីកអំណាចរបស់ទ្រង់ គ្របដណ្ដប់ទៅលើប្រទេសជិតខាងស្ទើរតែទាំងអស់នៅក្នុងតំបន់មជ្ឈិមបូព៌ា។ ព្រះអង្គព្រមជាមួយនិងព្រះរាជអគ្គមហេសី ជាទីស្រលាញ់ស្មើនឹងព្រះនេត្ររបស់ទ្រង់ បានគ្រប់គ្រងនូវអាណាចក្រដ៏ធំធេង (រួមបញ្ចូលទាំងប្រទេសចំណុះផងដែរ) អស់រយៈពេលជាង២៤ឆ្នាំ។ ប៉ុន្តែជាអកុសល នៅឆ្នាំ៣៥៣មុន គ.ស ព្រះចៅម៉ូសូលុស ទ្រង់បានសោយទិវង្គត់ចោលព្រះនាងអាធេមីសៀ ដែលក៏ត្រូវជាប្អូនស្រីបង្កើតរបស់ទ្រង់ (វាជាប្រពៃណីរបស់អ្នកស្រុកហាលីខាណាស៊ុសនាយុគសម័យនោះ ដែលមហាក្សត្រគ្រប់ព្រះអង្គចាំបាច់ត្រូវតែរៀបអភិសេក ជាមួយនឹងព្រះកនិដ្ឋភគិនីរបស់ខ្លួនឯង ដូចគ្នានឹងប្រពៃណីរបស់ប្រទេសឥណ្ឌា នាសម័យបុរាណផងដែរ) ឱ្យរស់រងទុក្ខធំព្រោះក្ដីអាឡោះអាល័យទៅដល់ទ្រង់ ដែលជាព្រះស្វាមី(តែក៏ត្រូវជាបងប្រុសបង្កើតផងដែរ) ឧបមាបីដូចសេចក្ដីទុក្ខសោករបស់នាងកង្រី ដែលត្រូវព្រាត់ប្ដីជារៀងរហូតយ៉ាងដូច្នោះដែរ (ឯកសារមួយចំនួនអះអាងថា ព្រះនាងទ្រង់សោយទុក្ខរីងរៃរហូតស្ទើរក្ស័យព្រះជន្ម



**ពិនិត្យមើលចុះបាទ! នេះឯងហើយរូបសំណាកព្រះចៅម៉ូសូលុស (បើសង្ហារម៉្លឹង១តើឱ្យព្រះនាងអាតេមីសៀជាច់ព្រះទ័យម្ដេចទៅកើត)**

ទៅតាមព្រះស្វាមីទៀតផង)។ ដោយអំណាចនៃទឹកចិត្តស្រលាញ់ និងក្ដីអាឡោះអាល័យរកទីបំផុតគ្មាន (ក្នុងជីវិតជាមនុស្សគឺពិតជាគ្មានអ្វីឈឺចាប់ជាជាងការបាត់បង់ នូវមនុស្សដែលខ្លួនស្រលាញ់នោះទេ) ក៏ដូចជាចង់សម្ដែងនូវការគោរព ចំពោះព្រះស្វាមីនេះឯងហើយទើបព្រះនាងទ្រង់បញ្ជារឱ្យសាងសង់នូវមហាចេតិយយក្ស (ហើយដែលក្រោយមកមានឈ្មោះល្បីកងរំពងនៅលើផែនដីនេះ) នេះឡើងទុកសម្រាប់ជាទីតម្កល់នូវព្រះសពរបស់ព្រះស្វាមី ដែលព្រះនាងស្រលាញ់ពេញចិត្តរកអ្វីប្រៀបផ្ទឹមគ្មាន។ វាជាស្ថាបត្យកម្មសំណង់ដ៏ល្អឯកមួយនៅលើពិភពលោក ហើយដែលត្រូវបានគេរាប់បញ្ចូលជាអច្ឆរិយវត្ថុមួយក្នុងចំណោមអច្ឆរិយវត្ថុទាំង៧នៃយុគបុរាណ។ តួមហាចេតិយមានរាងបួនជ្រុងមានបណ្ដោយប្រវែង៣៨ម៉ែត្រ និងទទឹង៣៣ម៉ែត្រ ផ្នែកខាងលើមានសសរថ្មកែវចំនួន៣៦ដើម រៀងជាជួរទ្រនូវដំបូល ដែលមានរាងស្រដៀងទៅនឹងពីរ៉ាមីត។



**នេះហើយបាទ! មហាចេតិយដែលត្រូវបានស្ថាបនាឡើងដោយក្តីស្រលាញ់**

បន្ទប់បញ្ចុះព្រះសព ហើយនិងមឈូសថ្មពណ៌ស ដែលប្រដាប់ដោយមាស និងគ្រឿងអលង្ការផ្សេងៗ ត្រូវបានតម្កល់នៅផ្នែកខាងលើនៃវេទិកាព័ទ្ធជុំវិញដោយសសរថ្មជាច្រើនដើម។ នៅខាងលើដំបូលមានរូបចម្លាក់រទេះ ដែលអូសដោយសេះចំនួន៤ក្បាល ដោយមានរូបព្រះចៅម៉ូសូលុស និងព្រះនាងអាធេមីសៀទ្រង់គង់ប្រថាប់នៅពីលើ។ មហាចេតិយម៉ូសូលៀមមានកម្ពស់ប្រហែល៤៥ម៉ែត្រ ចែកចេញជាបួនថ្នាក់គឺ

១.វេទិកាមាន កម្ពស់ ២០ម៉ែត្រ

២.សសរស្តម្ភមានកម្ពស់ ១២ម៉ែត្រ

៣.ដំបូលដែលមានរាងស្រដៀង ទៅនឹងពីរ៉ាមីតមាន កម្ពស់ ៧ម៉ែត្រ

៤.រូបសំណាកព្រះចៅម៉ូសូលុស និងព្រះនាងអាធេមីសៀទ្រង់គង់ប្រថាប់នៅពីលើព្រះរាជរថ (រទេះសេះ) ស្ថិតនៅលើដំបូលមហាចេតិយកម្ពស់៦ម៉ែត្រ។

មិនគ្រាន់តែទំហំនៃស្ថាបនកម្ម ដ៏មហិមារបស់វាប៉ុណ្ណោះទេ ដែលធ្វើឱ្យមហាចេតិយនៃព្រះចៅម៉ូសូលុស មានភាពស្រស់ស្អាត ប៉ុន្តែវានៅមានក្បាច់ចម្លាក់យ៉ាងល្អវិចិត្រ រួមជាមួយនឹងរូបបដិមាជាច្រើន ដែលត្រូវបានគេប្រដាប់តាក់តែងនៅតាមថ្នាក់និមួយៗ បូករួមទាំងដំបូលផងដែរ។ គ្រប់រូបបដិមានិមួយៗដែលរួមមាន រូបមនុស្ស សត្វតោ សត្វសេះ និងសត្វជាច្រើនផ្សេងទៀត សុទ្ធតែត្រូវបានដាប់ឆ្លាក់យ៉ាងផ្ចិតផ្ចង់ ដោយស្ថាបត្យករស្នាដៃឯក ប្រចាំយុគសម័យនោះ(សូមពិនិត្យមើលរូបនៅទំព័រទី៧១) ។

ភ្លាមៗបន្ទាប់ពីគ្រោងសំណង់ទាំងមូល កំពុងត្រូវបានចាប់ផ្តើមស្ថាបនា ព្រះនាងអាធេមីសៀក៏ជួបប្រទះនូវបញ្ហាដ៏ស្មុគស្មាញមួយ នោះគឺការបះបោររបស់នគរ ដែលស្ថិតនៅក្រោមចំណុះការគ្រប់គ្រង នៃអតីតស្វាមីរបស់ព្រះនាង ក្រោយដែលពួកគេបានទទួលដំណឹង ស្តីអំពីការសោយទីវង្គត់ នៃព្រះចៅម៉ូសូលុស។ នាវាចម្បាំងជាច្រើននៃនគរ **រ៉ូដស៍** (នគរចំណុះ) ត្រូវបានបញ្ជូនមកដើម្បីឡោមព័ទ្ធរាជធានីហាលីខាណាស៊ុស ។ មិនបង្អង់យូរក្រោយទទួលបានពត៌មាន អំពីការលើកទ័ពចូលមករបស់សត្រូវ ព្រះនាងអាធេមីសៀបានទ្រង់ភៀសព្រះកាយ ជាមួយនឹងនាវា

ផ្កាល់របស់ព្រះនាងទៅពួនស្ពាក់ នៅក្បែរកំពង់ផែប៉ែកខាងកើតនៃទីក្រុង ។



**មហាចេតិយម៉ូសូលៀមមើលពីខាងលើ**

ជាសំណាងល្អគឺកងទ័ពរបស់សត្រូវ បានទទួលរងនូវការបរាជ័យយ៉ាងធ្ងន់ធ្ងរ ក្រោមការវាយឆ្មក់នៃកងទ័ព ដែលដឹកនាំបញ្ជារដោយព្រះនាងផ្ទាល់ ក្នុងខណៈដែលពួកគេកំពុងឡើងគោក ក្នុងបំណងវាយលុកចូលមកក្នុងរាជធានី។ ដោយព្រះទ័យចង់សងសឹក ព្រះនាងអាធេមីសៀ មិនព្រមបញ្ឈប់ត្រឹមការវាយឆ្មក់រហូតធ្វើឱ្យសត្រូវបាក់ទ័ព ចូលទៅកាន់ឈូងសមុទ្រនោះឡើយ (ប្រហែលជាទ្រង់ចង់បង្ហាញឱ្យពិភពលោកបានដឹងថា ទោះបីព្រះនាងជាស្ត្រីមេម៉ាយ ដែលប្តីស្លាប់ចោលក៏ដោយក៏មិនមែនថានណារៗ សុទ្ធតែអាចធ្វើបាបបានដោយងាយៗនោះដែរ) ប៉ុន្តែទ្រង់នៅបានបញ្ជារឱ្យពលទាហានរបស់ព្រះនាង បន្លំខ្លួនជិះនៅលើនាវារបស់សត្រូវ ដែលពួកគេវាយយកបាន រួចហើយធ្វើដំណើរឆ្ពោះតម្រង់ទៅរកនគររ៉ូដស៏ ដើម្បីធ្វើនូវអ្វីដែលទ្រង់គិតថា អាចនឹងធ្វើឱ្យទ្រង់រសាយកំហឹង។ ចំណែកឯស្តេចនគររ៉ូដស៏ពេលដែលឃើញនាវាទាំងឡាយនោះក៏នឹកស្មានថា ជាទ័ពរបស់ខ្លួនដែលច្បាំងឈ្នះត្រលប់មកវិញ ទើបបណ្តាលឱ្យធ្វេសប្រហែសក្នុងការការពារ ជាហេតុធ្វើឱ្យកងទ័ពរបស់ព្រះនាងអាធេមីសៀអាចវាយដណ្តើមកាន់កាប់ទីក្រុងរ៉ូដស៏ បានយ៉ាងងាយបំផុត។



មឈូសថ្មកែវពណ៌សដ៏ស្រស់ស្អាតដែលតម្កល់ នូវព្រះសពព្រះចៅម៉ូសូលុស និងព្រះនាងអាធេមីសៀ

មហាចេតិយម៉ូសូលៀម នៃទីក្រុងហាលីខាណាស៊ុសនេះ តាំងនៅបានអស់រយៈពេលជាច្រើនសតវត្សន៍ក្រោយមកទៀត ដោយពុំមានទទួលរងនូវការបំផ្លិចបំផ្លាញណាមួយឡើយ សូម្បីតែក្នុងសម័យដែលរាជធានីនេះធ្លាក់ទៅក្រោមការគ្រប់គ្រងរបស់ព្រះចៅចក្រពត្តិ**អាឡិច សាន់ឌឺរ** នៃនគរម៉ាសិដូនៀ ក្នុងឆ្នាំ៣៣៤មុនគ.ស ឬសូម្បីតែនៅក្នុងពេលដែលវាត្រូវបានលុកលុយ ដោយក្រុមចោរចល័តនៅក្នុងឆ្នាំ៦២និង៥៨មុនគ.សក៏ដោយ ក៏វានៅតែឈរបង្ហួតរាងយ៉ាងសង្ហារ ក្នុងទីក្រុងដែលទទួលរងនូវការបំផ្លាញ អស់រយៈពេលជាង១៧សតវត្សន៍។

មិនខុសគ្នាទៅនឹងឧទ្យានបណ្ដែតបាប៊ីឡូន សើនហ្វារ៉ូ ឬទេវរូបខូឡូស៊ុសប៉ុន្មានឡើយ មហាចេតិយដ៏គួរឱ្យកោតស្ញប់ស្ញែងមួយនេះ ត្រូវបានបំផ្លាញខ្ទេចខ្ទីស្ទើរតែទាំងស្រុងដោយគ្រោះរញ្ជួយដី នៅក្នុងឆ្នាំ១៤០៤នៃគ.ស (ជាអំឡុងពេលដែលអាណាចក្រខ្មែរដ៏ល្បីរន្ទឺ កំពុងត្រូវបានរុករានទន្ទ្រានដោយកងទ័ពសៀម) បន្សល់នៅត្រឹមខឿនសំណង់ផ្នែកខាងក្រោម ឱ្យយើងបានឃើញរហូតមកដល់បច្ចុប្បន្ននេះប៉ុណ្ណោះ។

នៅក្នុងសតវត្សន៍ទី១៣ (មួយសតវត្សន៍មុនគ្រោះរញ្ជួយដី) ពួក**ឃ្រូសេដ** (Crusaders) ដែលបានគ្រប់គ្រងទីក្រុងហាលីខាណាស៊ុស បានរើយកថ្មពីមហាចេតិយម៉ូសូលៀម ដើម្បីទៅកសាងជាមហាកំពែងសេន ពីទើរ៍(បច្ចុប្បន្នស្ថិតនៅក្នុងទីក្រុងបតរ៉ាំ) ទុកសម្រាប់តស៊ូជាមួយនឹង សត្រូវផ្នែកសាសនារបស់ខ្លួន។ អ្វីដែលរឹតតែអាក្រក់ជាងនេះទៅទៀត គឺនៅក្នុងឆ្នាំ១៥២២ ពតិមានស្ដីអំពីការលើកទ័ពចូលលុកលុយរបស់ទួរគី បានបណ្ដាលឱ្យពួកឃ្រូសេដ រឹងរឹតតែបំផ្លាញនូវមហា




រូបគំនូរមហាចេតិយម៉ូសូលៀមដែលគូរដោយ
វិចិត្រករផ្សេងៗគ្នា (សូមពិនិត្យមើលឈ្មោះ
វិចិត្រករ និងកាលបរិច្ឆេទនៅក្រោមរូបគំនូរនិមួយៗ)

ចេតិយដែលស្ថាបនាឡើងដោយក្តីស្រលាញ់ របស់ព្រះនាងអាធេមីសៀ (ប្រសិនបើព្រះវិញ្ញាណក្ខន្ធរបស់ព្រះនាង ទ្រង់បានជ្រាបនូវរឿងនេះមិនដឹងថា តើទ្រង់ឈឺចាប់និងចងកំហឹងប៉ុណ្ណាទេ) ដើម្បីយកថ្មពីមហាចេតិយដែលសល់ពីការបំផ្លាញ ដោយការរញ្ជួយដីទៅស្ថាបនាមហាកំពែងរបស់ពួកគេ ឱ្យកាន់តែមានភាពរឹងមាំខ្លាំងឡើងថែមទៀត។

ក្នុងឆ្នាំ១៨៤៦អាជ្ញាធរនៃសារៈមន្ទីរជាតិអង់គ្លេស បានបញ្ជូនលោក**ឆាលេ ថូម៉ាស់ ញូតុន** (Charles Thomas Newton) ទៅកាន់ប្រទេសទួរគីដើម្បីធ្វើការរុករកនូវមហាចេតិយម៉ូសូលៀម (នេះជាទង្វើដែលប្រទេសពួកលោកខាងលិចមួយចំនួន និយមនាំគ្នាធ្វើក្នុងបំណងប្រមូលរូបរួមយក(លួចប្លន់) នូវស្នាដៃសិល្បៈដ៏មានតម្លៃជុំវិញពិភពលោក យកទៅតម្កល់ទុកនៅប្រទេសរបស់ខ្លួន ដែលវាមិនខុសគ្នាទៅនឹងអ្វី ដែលបារាំងបានធ្វើមកលើប្រទេសកម្ពុជា ក្នុងអំឡុងការត្រួតត្រាអស់រយៈពេលជិតមួយសតវត្សន៏របស់ខ្លួនមកលើប្រទេសនេះ ហើយជាលទ្ធផលគឺបារាំងបានប្រមូលយកវត្ថុដ៏មានតម្លៃខាងសិល្បៈកម្ម ដែលមិនអាចកាត់ថ្លៃបានរបស់ខ្មែរអស់ជាច្រើនអនេក យកទៅតម្កល់ទុកនៅប្រទេសរបស់ខ្លួន)។ វាពិតជាមានការលំបាកមិនតិចទេសម្រាប់លោកញូតុន ព្រោះថាគាត់មិនបានដឹងច្បាស់ អំពីទីតាំងពិតនៃមហាចេតិយ ម្យ៉ាងទៀតត្រូវចំណាយប្រាក់យ៉ាងច្រើនក្នុងការទិញដីដើម្បីធ្វើការជីករុករក ដែលដំបូងៗវាហាក់ដូចជា មិនបានទទួលលទ្ធផលអ្វីទាំងអស់។ ទុកជាយ៉ាងណាក៏ដោយ ក្រោយមកទៀតគាត់បានសម្រេចចិត្ត ធ្វើការសិក្សាស្វែងយល់អំពីកំណត់ត្រារបស់ប្រវត្តិវិទូសម័យបុរាណមួយចំនួនដូចជា កំណត់ត្រារបស់លោក

ភ្លឺនីវិញម្តង ដើម្បីជាជំនួយដល់ការរុករក សំដៅឈានទៅដល់ការសន្និដ្ឋាន នូវទីតាំងណាមួយដែលគាត់គិតថា វាអាចជាទីតាំងពិតប្រាកដនៃមហាចេតិយដែលគាត់កំពុងស្វែងរក មុននឹងសម្រេចចិត្តទិញដីដើម្បីធ្វើការជីករុករក ។




ចម្លាក់សេះថ្មមួយ ក្នុងចំណោមសេះទាំង៤ ដែលអូសទូវព្រះរាជរថ ហើយត្រូវបានឆ្លាក់នៅលើដំបូលនៃមហាចេតិយម៉ូសូលៀម បច្ចុប្បន្នស្ថិតនៅក្នុងសារៈមន្ទីរនាប្រទេសអង់គ្លេស

គាត់បានបន្តការជីករុករករបស់គាត់ តទៅទៀតតាមរយៈការជីករូងក្រោមដី (គាត់មិនចង់ចំណាយប្រាក់ច្រើនសម្រាប់ទិញដី)។ ដោយវិធីនេះគាត់បានប្រទះឃើញនូវជញ្ជាំង និងជណ្តើរព្រមទាំងជ្រុងបីផ្សេងទៀតនៃមហាចេតិយ ដែលជួយឱ្យគាត់ប្រាកដនៅក្នុងចិត្តថា តើដីត្រង់ណាដែលគួរទិញយកសម្រាប់ ការស្រាវជ្រាវរបស់គាត់។ បន្ទាប់ពីនោះមកទៀត គាត់បានរុករកឃើញនូវ គ្រោងសំណង់នៃចេតិយទាំងមូលដែលនៅសេសសល់ពីគ្រោះរញ្ជួយដី និងការបំផ្លាញរបស់ពួកឃ្យូសេដ រួមបញ្ចូលទាំងរូបសំណាកព្រះរាជរថ (រទេះសេះ)ដែលតាំងនៅផ្នែកខាងលើដំបូលនៃចេតិយ និងរូបសំណាកព្រះចៅម៉ូសូលុស ព្រមទាំងព្រះអគ្គទេពីរបស់ព្រះអង្គផងដែរ ។



**គំនរបាក់បែកដែលបន្សល់ទុកនៅ នាទីតាំងនៃមហាចេតិយម៉ូសូលៀម**

បច្ចុប្បន្នស្នាដៃនៃសិល្បៈទាំងនេះ ត្រូវបានតម្កល់ទុកនៅក្នុងបន្ទប់ ដែលគេឱ្យឈ្មោះថា " ម៉ូសូលៀម " នាសារៈមន្ទីរជាតិអង់គ្លេស ជាទីដែលរូបសំណាកព្រះចៅម៉ូសូលុស និងព្រះនាងអាធេមីសៀ ឈរទតមើលនូវគំនរបាក់បែកនៃមហាចេតិយ ដ៏ស្រស់ស្អាត ដែលព្រះនាងខិតខំសាងថ្វាយព្រះស្វាមី........។




- ឈ្មោះ : សើនហ្វារ៉ូ
- ទីតាំង : ស្ថិតនៅក្នុងទីក្រុងអាឡិចសាន់ដ្រា ប្រទេសអេហ្ស៊ីប
- ឆ្នាំកសាង : ២៧០មុន គ.ស
- កសាងដោយ : ព្រះចៅប៉ះតូលេមី សូធើរ៍
- វត្ថុបំណង : ឧទ្ទិសចំពោះអាទិទេពនៃការជួយសង្គ្រោះ ក៏ដូចជាសម្រាប់ធ្វើជានិមិត្តសញ្ញាកំណត់ទិសក្នុងការធ្វើនាវាចរណ៍ និងសម្រាប់ឃ្លាំមើលសកម្មភាពរបស់សត្រូវផងដែរ ។

-បច្ចុប្បន្នគ្មានអ្វីបន្សល់ទុកនៅឡើយ( រងគ្រោះដោយរញ្ជួយដីនៅក្នុងឆ្នាំ ១៣០៣ និង១៣២៣នៃគ.ស ។

*សេីន (នាម) : ប៉មខ្ពស់ស្រឡះកដោយឥដ្ឋជាដេីមសម្រាប់អុជភ្លេីងបំភ្លឺ ជាគ្រឿងចំណាំជ្រុងជ្រោយទន្លេ ឬសមុទ្រ កុំឱ្យអ្នកដំណេីរជេីងទឹកវង្វេងផ្លូវ ក្នុងពេលយប់ ឬសម្រាប់ឡេីងថ្កោលមេីលដំណេីរ ចេញចូលនៃអ្នកនាំទំនិញរំលងគយ ឬក៏សម្រាប់ឡេីងថ្កោលមេីល ដំណេីរលបចូលមកនៃពួកបច្ចាមិត្រ។

---

ក្នុងបណ្តាអច្ឆរិយវត្ថុទាំង៧នៃលោកបុរាណ គឺមានត្រឹមតែមួយប៉ុណ្ណោះ ដែលត្រូវបានគេសាងឡេីងមក ដេីម្បីបំរេីឱ្យផលប្រយោជន៍រួម (ផលប្រយោជន៍នគរ) បន្ថែមទៅលេីសម្រស់ដ៏ល្អឯក ខាងផ្នែកសិល្បៈកម្មរបស់វា (អច្ឆរិយវត្ថុដ៏ទៃទៀតគ្រាន់តែត្រូវបានសាងឡេីង សម្រាប់ជាទីតម្កល់សព ជាទីកំសាន្ត ឬគ្រាន់តែជាទីសម្រាប់ធ្វេីសក្ការៈបូជា ចំពោះអង្គអាទិទេពប៉ុណ្ណោះ) នោះគឺ " **សេីន ហ្វារ៉ូ នាអាឡិចសាន់ឌ្រា** "។

សម្រាប់នាវិកទាំងឡាយ វាគឺជាទីតាំងមួយ ដែលជួយឱ្យពួកគេងាយស្រួលកំណត់ទិសក្នុងការធ្វេីដំណេីរតាមផ្លូវទឹករបស់គេ (ឯកសារជាច្រេីនបានបញ្ជាក់ថា គេអាចមេីលវាឃេីញបានយ៉ាងច្បាស់ ក្នុងចម្ងាយដល់ទៅជាង៥០គីឡូម៉ែត្រពីច្រាំងសមុទ្រ)។ ប៉ុន្តែប្រសិនបេីយេីង និយាយអំពីតម្លៃខាងផ្នែកសិល្បៈកម្មវិញ វាគឺជាសំណង់មួយដែលខ្ពស់ជាងគេបំផុត នៅលេីលោកនាយុគបុរាណ (បន្ទាប់ពីមហាពីរ៉ាមីតនាហ្គីហ្សា)។ ដោយឡែកសម្រាប់ពួកអ្នកវិទ្យាសាស្ត្រទាំងឡាយ វាមានភាពអស្ចារ្យនៅត្រង់កញ្ចក់អាថ៌កំបាំង ដែលទាញចិត្តពួកគេឱ្យឈ្លក់វង្វេងបាន នោះគឺកញ្ចក់ដែលអាចឆ្លុះឃេីញ ដល់ទៅរយៈចម្ងាយជាង៥០គ.ម ពីច្រាំងសមុទ្រ។

វាមានទីតាំងស្ថិតនៅលេីកោះមួយ ដែលមានឈ្មោះថា **ហ្វារ៉ូស** (Pharos)



នេះឯងហើយសើនហ្វារ៉ូដ៏អស្ចារ្យគ្មានពីរនៅក្នុងលោក
មានកម្ពស់ខ្ពស់កប់ពពកជាមួយនិងគប់ភ្លើងដ៏ធំមហិមានៅខាងលើដ៏គួរឱ្យកត់សំគាល់ពិសេស

ហើយសព្វថ្ងៃ ស្ថិតនៅក្នុងទីក្រុងអាឡិចសាន់ដ្រានៃប្រទេសអេហ្ស៊ីប ។ ចំពោះរឿងរ៉ាវដែលទាក់ទងនឹងសើនហ្វារ៉ូនេះ មានកំនត់ហេតុខ្លះបានសរសេរទុកយ៉ាងដូច្នេះថា

នៅក្នុងឆ្នាំ៣២៣មុនគ.ស មិនយូរប៉ុន្មានបន្ទាប់អំពីការសោយទីវង្គត់ នៃព្រះចៅចក្រពត្តិអាឡិច សាន់ដឺរ៍ មេទ័ពរបស់ព្រះអង្គឈ្មោះប៉ះតូលេមី សូធើរ៍ (Ptolemy Soter) បានគ្រប់គ្រងអំណាចនៅក្នុងប្រទេសអេហ្ស៊ីបទាំងមូល ដោយបានតាំងរាជធានីនៅអាឡិចសាន់ដ្រា ។ ឃ្លាតឆ្ងាយពីទីក្រុងនេះបន្តិច ស្ថិតនៅតាមបណ្តោយឆ្នេរសមុទ្រ មានកោះមួយឈ្មោះថាហ្វារ៉ូស ជាកោះដែលត្រូវបានគេតភ្ជាប់ទៅនឹងដីគោក ដោយទំនប់ដ៏ធំមួយ ដែលធ្វើឱ្យទីក្រុងមួយនេះក្លាយទៅជាទីក្រុង ដែលមានកំពង់ផែ២ ។

អាស្រ័យដោយសណ្ឋានដីមាត់សមុទ្រ ដែលមានលក្ខណៈរាបស្មើ បូករួមនិងល័ក្ខខ័ណ្ឌមិនអំណោយផលមួយចំនួន នៅក្នុងការធ្វើនាវាចរណ៍ទើបធ្វើឱ្យស្ថាបត្យកម្មមួយ ក្នុងចំណោមស្ថាបត្យកម្មដ៏អស្ចារ្យទាំង៧នៅក្នុងលោក ត្រូវបានគេកសាងឡើងនៅទីនេះ ។ គំរោងសាងសង់នេះ ត្រូវបានផ្តួចផ្តើមគំនិតនិងបញ្ជារឱ្យសាងសង់ឡើងដោយព្រះចៅប៉ះតូលេមី សូធើរ៍ ក្នុងអំឡុងឆ្នាំ២៩០មុនគ.ស និងត្រូវបានបញ្ចប់ជាស្ថាពរ នៅក្នុងរាជ្យនៃបុត្រារបស់ព្រះអង្គ គឺព្រះចៅប៉ះតូលេមីហ្វីឡាដាហ្វ៊ុស (Ptolemy Phyladaphus) ។ ស្ថាបនិកដែលស្ថាបនានូវមហាសំណង់ដ៏អស្ចារ្យនេះគឺលោកសូស្ត្រាទុស (Sostratus) ។ វាត្រូវបានសាងឡើងដើម្បីឧទ្ទិសដល់ព្រះចៅប៉ះតូលេមី សូធើរ៍ និងព្រះរាជអគ្គមហេសីរបស់ព្រះអង្គ ព្រះនាងបេរ៉េនីស ដែលក្សត្រទាំងពីរទ្រង់ជាតំណាងឱ្យអាទិទេព នៃការជួយសង្គ្រោះជីវិត ។



រូបភាពបង្ហាញពីពន្លឺដែលជះចេញពីកញ្ចក់ពិសេស ដែលស្ថិតនៅផ្នែកខាងលើនៃសេីនហ្វារ៉ូ

អស់រយៈពេលជាច្រើនសតវត្សន៍ ដែលសេីននៃទីក្រុងអាឡិចសាន់ដ្រា (ពេលខ្លះត្រូវបានគេហៅថាសេីនហ្វារ៉ូ ព្រោះអាស្រ័យស្ថិតនៅលេីកោះហ្វារ៉ូ) ត្រូវបានប្រេីប្រាស់សម្រាប់សំគាល់ទីតាំងនៃកំពង់ផែ តាមរយៈការដុតបំភ្លឺភ្លេីងនៅពេលយប់ និងការចាំងត្រលប់នៃពន្លឺថ្ងៃ ជាមួយកញ្ចក់មួយផ្ទាំងដ៏ធំ នៅផ្នែកខាងលេី នាពេលថ្ងៃ (ដេីម្បីឱ្យមានភាពងាយស្រួលក្នុងការមេីលពីចម្ងាយ)។

កញ្ចក់នៅផ្នែកខាងលេីនៃសេីនហ្វារ៉ូនេះ ក្រោយមកត្រូវបានគេយកចុះមកខាងក្រោម ដោយពុំត្រូវបានយកទៅដាក់ នៅត្រង់កន្លែងដេីមវិញឡេីយ ហេីយទីបំផុតក៏ត្រូវធ្លាក់បែកខ្ទេចខ្ទី ដោយមិនអាចជួសជុលឡេីងវិញបានឡេីយ(ពិតជាគួរឱ្យសោកស្ដាយខ្លាំងណាស់ មិនដូច្នោះទេប្រាកដជាមនុស្សជំនាន់ក្រោយដូចជា ខ្ញុំហេីយនិងមិត្តអ្នកអានទាំងឡាយ បានឃេីញពីភាពអស្ចារ្យរបស់វាជាមិនខាន)។

តាមរយៈកំណត់ហេតុមួយចំនួន កត់ត្រាដោយប្រវត្តិវិទូសម័យបុរាណ ដូចជាលោក**ស្ត្រាបូ** ហេីយនិងលោក**ភ្លីនី** (Strabo and Pliny) ជាដេីម សុទ្ធសឹងតែបានផ្ដល់ឱ្យយេីង នូវបទពណ៌នាខ្លីៗមួយចំនួនស្ដីអំពី សេីនហ្វារ៉ូដ៏ល្បីល្បាញព្រមទាំងកញ្ចក់អាថ៌កំបាំងមួយនេះផងដែរ។ កំណត់ហេតុទាំងនោះ បានប្រាប់ឱ្យយេីងដឹងអំពីថា តេីកញ្ចក់ដ៏អស្ចារ្យដែលស្ថិតនៅផ្នែកខាងលេីនៃសេីនហ្វារ៉ូនេះ អាចជះពន្លឺបានរហូតដល់ទៅជាង៥០គីឡូម៉ែត្រ បានយ៉ាងដូចម្ដេច? បេីតាមការនិទាន កញ្ចក់ដ៏អស្ចារ្យមួយនេះ ក្រៅពីត្រូវបានប្រេីសម្រាប់ ជួយតម្រង់ទិសនាវាទាំងឡាយ នាពេលថ្ងៃហេីយនោះ វាក៏ត្រូវបានគេប្រេីសម្រាប់ ការពារទីក្រុងអាឡិចសាន់ដ្រា ពីការរុករានរបស់សត្រូវផងដែរ តាមរយៈការបញ្ចាំងពន្លឺថ្ងៃដែលជះចេញពីផ្ទៃកញ្ចក់

ទៅដុតបំផ្លាញនាវាទាំងឡាយរបស់សត្រូវ ដែលកំពុងធ្វើដំណើរចូលមកវាយលុកទីក្រុងមួយនេះបានថែមទៀតផង (អច្ឆរិយៈ...!!) ។



រូបមួយផ្សេងទៀតនៃសើនហ្វារ៉ូដែលមានកម្ពស់៤ជាន់និងមានរូបបុព្រាសមុទ្រទេពនៅខាងលើ

សើនហ្វារ៉ូនេះក្រោយមកទៀត ត្រូវបានពួករ៉ូម៉ាំងឆ្លាក់រូបរបស់វានៅលើប្រាក់កាក់ ដែលគេប្រើប្រាស់សម្រាប់ចាយវាយនាសម័យនោះផងដែរ ដែលមិនខុសអ្វីទៅនឹងការបោះពុម្ពរូបស្ថាបត្យកម្មសំណង់ដ៏ល្បីៗ នៅលើក្រដាស់ប្រាក់ នាសម័យបច្ចុប្បន្នយើងនេះដែរ ។ ក្នុងសម័យដែលពួកអារ៉ាប់លុកលុយអេហ្ស៊ីប ពួកគេបានកោតសរសើរនូវ ភាពសំបូរស្តុកស្តម្ភនៃទីក្រុងអាឡិចសាន់ដ្រា រួមទាំងភាពអស្ចារ្យ



គំនូរដែលគូរដោយវិចិត្រករនៅសតវត្សន៍ទី១៩បង្ហាញពីសើន
ហ្វារ៉ូដែលមានកម្ពស់ដល់ទៅ១២ជាន់មានគប់ភ្លើងដ៏ធំមហិមា
នៅខាងលើជំនួសឱ្យ រូបបុព្រាសមុទ្រទេព និងកញ្ចក់ពិសេស

នៃសើនហ្វារ៉ូ តាមរយៈកំណត់ត្រាផ្សេងៗរបស់ពួកគេ ក៏ដូចជាកំណត់ហេតុដែលសរសេរឡើង ដោយអ្នកធ្វើដំណើរជាច្រើន នាយុគសម័យនោះផងដែរ ។

ក្នុងឆ្នាំ១១៦៦នៃគ.ស អ្នកដំណើរជនជាតិអារ៉ាប់ម្នាក់ឈ្មោះ**អាប៊ូ ហាកាំង អាល់អាន់ដា លូស៊ី** (A bou- Haggag Al-Andaloussi) បានធ្វើដំណើរទៅកាន់អេហ្ស៊ីប ហើយបានកត់ត្រានូវរឿងរ៉ាវយ៉ាងពិស្តារ ទាក់ទងទៅនឹងលក្ខណៈទ្រង់ទ្រាយនៃសើនហ្វារ៉ូនេះ ដែលអាចជួយឱ្យអ្នកបុរាណវិទ្យាសម័យថ្មី ងាយស្រួលក្នុងការជួសជុលស្ថាបនាវាសាឡើងវិញ ។ គ្រោងសំណង់ទាំងមូល ត្រូវបានស្ថាបនាឡើងជាបីថ្នាក់ ដោយថ្នាក់ខាងក្រោមបំផុតមានរាង៤ជ្រុង និងមានកម្ពស់៥៥.៩ម៉ែត្រ ផ្នែកកណ្តាលមានរាង៨ជ្រុង ដោយជ្រុងនិមួយៗមានប្រវែង១៨.៣ម៉ែត្រ ហើយនិងកម្ពស់២៧.៤៥ម៉ែត្រ រីឯផ្នែកខាងលើបំផុតមានរាងមូលនិងមានកម្ពស់៧.៣ម៉ែត្រ ។ បើគិតពីកម្ពស់សរុបនៃសើនហ្វារ៉ូនេះ បូករួមទាំងខឿនសំណង់ ផ្នែកខាងក្រោមផងនោះ គឺវាមានកម្ពស់ដល់ទៅ១១៧ម៉ែត្រ ពោលគឺសមមូលទៅនឹង អគារដែលមានកម្ពស់៤០ជាន់ នាយុគសម័យទំនើបរបស់យើងនេះ (សូមកុំច្រលំទៅ នឹងសំណង់ផ្ទះល្វែងនៅប្រទេសរបស់យើង ដែលជាមធ្យមមានកម្ពស់ចាប់ពី៤ទៅ៥ម៉ែត្រ ព្រោះថា យើងមានធ្វើជាន់តឿនៅផ្នែកខាងក្នុង ខុសគ្នាទៅនឹងសំណង់អគារខ្ពស់ៗ ដែលជាមធ្យមមានកម្ពស់ត្រឹម៣ម៉ែត្រប៉ុណ្ណោះក្នុងមួយជាន់) ។ ក្នុងថ្នាក់និមួយៗមានរ៉កដែលប្រើសម្រាប់ផ្ទុកប្រេងសណ្តោងឡើងយកទៅ សម្រាប់ដុតចង្កៀង មិនត្រឹមតែប៉ុណ្ណោះទេ នៅមានការបូមទឹកសម្រាប់ យកឡើងទៅប្រើប្រាស់ដល់ជាន់លើបំផុតបានយ៉ាងងាយស្រួលទៀតផង ។ នៅខាងលើកំពូលនៃសើននេះ ក៏មានឆ្លាក់ជារូប

ចម្លាក់ព្រះបុត្រា របស់សមុទ្រទេព ( អាទិទេពដែលថែរក្សាសមុទ្រ) ផងដែរ ។

**សម្រស់របស់ស៊ើនហ្វារ៉ូ មើលពីចម្ងាយនាពេលរាត្រី**



ចាត់ទុកថាជាមហាសំណង់ដ៏អស្ចារ្យបំផុត ដែលអាចនៅស្ថិតស្ថេរគង់វង្សបានរហូតដល់ទៅជាង១៥០០ឆ្នាំ ទុកណាជាត្រូវទទួលរងនូវគ្រោះរញ្ជួយដី នៅក្នុងឆ្នាំ៩៥៦នៃគ.សក៏ដោយ ក៏មិនបានបណ្តាលឱ្យមានការខូចខាតធ្ងន់ធ្ងរណាស់ណាដែរ ។ ប៉ុន្តែតើមានមហាសំណង់ណា ដែលអាចទ្រាំទ្រទៅនឹងការចាប់អង្រួនរបស់ព្រះម៉ែធរណី បានម្តងហើយម្តងទៀតនោះ ហេតុដូច្នោះហើយបានជាមហាសំណង់ដ៏អស្ចារ្យមួយនេះ ត្រូវបានវិនាសស្ទើរតែទាំងស្រុង ដោយគ្រោះរញ្ជួយដីដ៏ខ្លាំងចំនួនពីរលើកផ្សេងទៀត នៅក្នុងឆ្នាំ១៣០៣និង១៣២៣នៃគ.ស ។ តមកទៀតនៅក្នុងឆ្នាំ១៣៤៩ លោក**អ៊ិន បាត់ទូតា** ដែលជាអ្នកដំណើរសញ្ជាតិអារ៉ាប់ ដ៏ល្បីល្បាញម្នាក់ បានទៅដល់ទីក្រុងអាឡិចសាន់ដ្រានេះ ប៉ុន្តែគួរឱ្យសោកស្តាយដោយគាត់

មិនអាចចូលទៅក្នុងសើនហ្វារ៉ូ ដែលបាក់បែកនេះបាន ឬសូម្បីតែឡើងទៅកាន់ច្រកចូល ក៏គាត់មិនអាចធ្វើទៅបានផងដែរ ។ សូមបញ្ជាក់ថាក្នុងចំណោមអច្ឆរិយវត្ថុទាំង៦នៃយុគបុរាណ ដែលត្រូវបានបំផ្លាញដោយគ្រោះធម្មជាតិ និងស្នាដៃមនុស្ស (លើកលែងតែមហាពីរ៉ាមីតមួយប៉ុណ្ណោះ) សើនហ្វារ៉ូ គឺជាអច្ឆរិយវត្ថុចុងក្រោយគេបំផុត ដែលបានទទួលរងនូវមហាវិនាសកម្មនេះ ។ ហេតុដូច្នេះហើយ ទើបយើងមានឯកសារគ្រប់គ្រាន់ និងច្បាស់លាស់ ទាក់ទងទៅនឹងប្រវត្តិក៏ដូចជាទីតាំង ព្រមទាំងលក្ខណៈទ្រង់ទ្រាយរបស់វា ។




តាមរយៈការធ្វើកំណាយនាសតវត្សន៍ទី២០ធ្វើឱ្យគេជឿថា សើនហ្វារ៉ូត្រូវតែមានរូបរាងយ៉ាងដូច្នេះ

ជំពូកចុងក្រោយបំផុត នៅក្នុងសៀវភៅប្រវត្តិសាស្ត្រ ទាក់ទងទៅនឹងសើនហ្វារ៉ូនេះ គឺរឿងរ៉ាវដែលកើតឡើងនៅឆ្នាំ១៤៨០នៃគ.ស ពេលដែលលោកម៉ាមី

លូកស៊ុលតង់ (MameloukSultan) សញ្ជាតិអេហ្ស៊ីបបានសម្រេចចិត្តសាងនូវកំពែង សម្រាប់ការពារទីក្រុងអាឡិចសាន់ដ្រា ។ គាត់បានសាងនូវបន្ទាយ ដែលមានលក្ខណៈជាស្ថាបត្យកម្មនាយុគសម័យកណ្ដាល នៅលើទីតាំងចាស់នៃសើនហ្វារ៉ូ ដោយប្រើនូវថ្មបាក់បែកដែលសល់ពីការរញ្ជួយដី បូករួមផ្សំជាមួយនឹងថ្មកែវមួយចំនួនផងដែរ ។

ស្ថាបត្យកម្មនៃសើនហ្វារ៉ូដ៏ល្បីរន្ទឺនេះ សម័យក្រោយមកទៀត ត្រូវបានគេយកទៅធ្វើជាគំរូក្នុងការស្ថាបនានូវសំណង់ជាច្រើន នៅតាមឈូងសមុទ្រមេឌីទែរ៉ាណេ រហូតទៅដល់អេស្ប៉ាញ ។ ប៉ុន្តែទុកជាសំណង់ដែលយកគំរូតាមសើនហ្វារ៉ូនេះត្រូវបានគេស្ថាបនានៅកន្លែងណាមួយ នៃពិភពលោកក៏ដោយចុះ វាក៏នៅតែត្រូវបានគេហៅថា " ហ្វារ៉ូ " ដដែល ។

បើទុកជាសើននៃទីក្រុងអាឡិចសាន់ដ្រាមួយនេះ មិនបានស្ថិតស្ថេរគង់វង្សរហូតមកដល់សព្វថ្ងៃនេះក៏ដោយចុះ ក៏វាបានបន្សល់ទុកនូវរឿងរ៉ាវនិងប្រវត្តិផ្សេងៗជាច្រើន ដែលបង្ហាញឱ្យមនុស្សជំនាន់ក្រោយ បានដឹងពីភាពអស្ចារ្យ នៃស្នាដៃរបស់ស្ថាបត្យករសម័យបុរាណ ក៏ដូចជាវប្បធម៌និងអរិយធម៌ របស់មនុស្សក្នុងយុគសម័យនោះ ។


អច្ឆរិយវត្ថុទាំង៧នៃយុគបុរាណ
៧. មហាទេវរូបខូឡូស៊ុស
The Colossus of Rhodes

- ឈ្មោះ : មហាទេវរូបខូឡូស៊ុស
- ទីតាំង : ស្ថិតនៅលើកោះរ៉ូដស៍ ប្រទេសក្រិច
- ឆ្នាំកសាង : ២៩៤មុន គ.ស
- កសាងដោយ : អ្នកស្រុកកោះរ៉ូដស៍
- វត្ថុបំណង : តំណាងឱ្យសន្តិភាព និងសាមគ្គីភាពរបស់អ្នកស្រុកកោះរ៉ូដស៍
- បច្ចុប្បន្នមិនមានអ្វីបន្សល់ទុកនៅឡើយ (រងគ្រោះដោយរញ្ជួយដីនៅឆ្នាំ ២២៦មុន គ.ស)

ជាមហាបដិមាករតំណាងឱ្យសុរិយទេព **ហេលីអូស** (Hellios) ដែលធ្វើអំពីសំរិទ្ធកម្ពស់៣៦.៥ម៉ែត្រ កសាងនៅក្នុងឆ្នាំ២៩៤មុនគ.ស ប្រើរយៈពេលក្នុងការកសាងអស់១២ឆ្នាំ ដោយស្ថាបនិកដ៏ល្បីល្បាញគឺលោក**ខារីស** (Chares) ហើយក្រោយមក ត្រូវបានបំផ្លាញខ្ទេចអស់គ្មានសល់ ដោយគ្រោះរញ្ជួយដីនៅរយៈពេលត្រឹម៥៦ឆ្នាំ បន្ទាប់ពីការសាងសង់ត្រូវបានបញ្ចប់។ ខូឡូស៊ុសមិនគ្រាន់តែជាទេវរូបដែលមានខ្នាតយក្សប៉ុណ្ណោះទេ តែវាថែមទាំងជានិមិត្តរូប នៃការឯកភាពគ្នារបស់ប្រជាជន ដែលរស់នៅលើកោះរ៉ូដស៍ដ៏ស្រស់ស្អាត នាយុគសម័យនោះផងដែរ។

វាមានទីតាំងនៅច្រកកំពង់ផែនៃកោះរ៉ូដស៍ ដែលបច្ចុប្បន្នស្ថិតក្នុងតំបន់ឈូងសមុទ្រមេឌីទែរ៉ានេ នាប្រទេសក្រិច។ ទេវរូបនេះមានកម្ពស់៣៦.៥ម៉ែត្រ ធ្វើអំពីថ្ម និងហ៊ុមព័ទ្ធដោយសំរិទ្ធនៅពីខាងក្រៅ ស្ថិតក្នុងឥរិយាបថឈរញែកជើងចេញពីគ្នា (កន្ធែកជើង) ដោយជើងទាំង២ស្ថិតនៅលើច្រាំងសងខាង នៃមាត់ច្រកចេញ



**មនុស្សសម័យថ្មីមួយចំនួនជឿថា មហាទេវរូបខូឡូស៊ុសដ៏ល្បីល្បាញ ត្រូវតែមានលក្ខណៈបែបនេះឯង**

ចូលនាកំពង់ផែរ៉ូដស៍ (នេះបើយោងតាមកំណត់ត្រាមួយចំនួន នាសម័យបុរាណ)។ ជាទេវរូបដែលត្រូវបានសាងសង់ឡើង ដើម្បីតំណាងឱ្យអាទិទេពហេលីអូស ដែលជាអាទិទេពដ៏ល្បីល្បាញមួយអង្គ នៅក្នុងជំនឿរបស់ជនជាតិក្រិចបុរាណសម្រាប់ទុកដូចជាអ្នកចាំយាមការពារច្រកកំពង់ផែដ៏សំខាន់នៃកោះរ៉ូដស៍។ ប៉ុន្តែជាមហាអកុសល គឺទេវរូបដែលឈរកាន់គប់ភ្លើងយ៉ាងសង្ហារនេះ ត្រូវបានវិនាសខូចខាតទៅវិញ ដោយគ្រោះរញ្ជួយដីដ៏ធំមួយ បន្ទាប់ពីការបង្ហាញខ្លួន ក្នុងនាមជាទេវរូបដ៏ធំជាងគេបំផុត នៅក្នុងលោកនាយុគសម័យនោះ បានត្រឹម៥៦ឆ្នាំប៉ុណ្ណោះ។

ភាគច្រើននៃរឿងរ៉ាវដែលទាក់ទងទៅនឹង មហាទេវរូបខូឡូស៊ុសនេះ គឺមានប្រភពមកពីសង្គ្រាម នៃការដណ្តើមទឹកដីគ្នា នៅក្នុងអាណាចក្រក្រិចបុរាណ ដោយមេដឹកនាំជាច្រើន នៅយុគសម័យនោះ។ ក្នុងឆ្នាំ៣៥៧មុនគ.ស កោះរ៉ូដស៍ ដែលជាទីតាំងនៃមហាទេវរូបនេះ ស្ថិតនៅក្រោមការត្រួតត្រា របស់ព្រះចៅអធិរាជម៉ូសូ លុស នៃនគរហាលីខាណាស៊ុស (The Mausolus of Halicarnassus) និង

តមកទៀត ធ្លាក់ទៅក្រោមការគ្រប់គ្រង របស់ព្រះចៅអធិរាជអាឡិច សាន់ដឺរ៍ នៅក្នុងឆ្នាំ៣៣២មុន គ.ស ។ នៅពេលអាឡិចសាន់ដឺរ៍ទ្រង់ចូលទិវង្គត់ នៅក្នុងឆ្នាំ៣២៣មុនគ.ស មេទ័ពទាំងឡាយរបស់ព្រះអង្គ បានច្បាំងគ្នាដើម្បីដណ្ដើមគ្រប់គ្រងអាណាចក្រដ៏មានវិសាលភាពធំល្វឹងល្វើយរបស់ទ្រង់ ប៉ុន្តែក្នុងចំណោមមេទ័ពទាំងនោះគឺមានតែមេទ័ពចំនួនបីរូបប៉ុណ្ណោះ ដែលបានទទួលជោគជ័យក្នុងការបែងចែកមហាអាណាចក្រនោះជាបីតំបន់ស្វយ័ត សម្រាប់គ្រប់គ្រងរៀង១ខ្លួន នោះគឺមេទ័ពដែលមានឈ្មោះថា**ប៉ះតូលេមី ,សេលូយូស និង អង់ទីហ្គើស** (Ptolemy, Seleu - cus, and Antigous) ។ ក្នុងមហាសង្គ្រាមបង្ហូរឈាមគ្រានោះ ព្រះចៅប៉ះតូ លេមីទ្រង់បានទទួលការគាំទ្រយ៉ាងខ្លាំងក្លា ពីសំណាក់អ្នកស្រុកកោះរ៉ូដស៍ ហើយដែលធ្វើឱ្យព្រះអង្គ ទ្រង់អាចវាយដណ្ដើមកាន់កាប់អេហ្ស៊ីបទាំងមូលបាន។ ទង្វើរបស់អ្នកស្រុកកោះរ៉ូដស៍នេះ បានធ្វើឱ្យព្រះចៅអង់ទីហ្គើសទ្រង់ខ្ញាល់ជាខ្លាំង ហើយក្រោយមកទៀតនៅក្នុងឆ្នាំ៣០៥មុនគ.ស ទ្រង់បានបញ្ជាឱ្យព្រះរាជបុត្ររបស់ព្រះអង្គព្រះនាមដេមេទ្រាស ដឹកនាំទ័ពចំនួន៤ម៉ឺននាក់ ដែលជាចំនួនមួយច្រើនជាងចំនួនអ្នកស្រុកដែលរស់នៅលើកោះរ៉ូដស៍ទៅទៀត ដើម្បីទៅវាយលុកដណ្ដើមយកកោះរ៉ូដស៍ មកដាក់ជាចំណុះរបស់ព្រះអង្គ។ សង្គ្រាមគ្រានោះបានបង្កឱ្យមាន ការស្លាប់និងរបួសជាច្រើន ប៉ុន្តែទុកជាយ៉ាងណាក្តី ក៏ទ័ពដែលដឹកនាំដោយព្រះអង្គម្ចាស់ដេមេទ្រាស មិនអាចវាយលុកដណ្ដើមយកកោះរ៉ូដស៍បានឡើយ ដោយទ្រង់បញ្ជាឱ្យដាក់ការឡោមព័ទ្ធជុំវិញកោះនោះ រហូតដល់ទៅរយៈពេលមួយឆ្នាំ។ ដំណឹងស្តីពីការឈ្លានពានកោះរ៉ូដស៍ ដោយកងទ័ពរបស់ព្រះអង្គម្ចាស់ដេមេទ្រាសនេះ ក្រោយ




បើតាមការស្រាវជ្រាវមួយចំនួនធ្វើឡើងនៅសតវត្សន៍ទី២០
ធ្វើឱ្យគេជឿថាទេវរូបខូឡូស៊ុសគួរតែមានរូបយ៉ាងដូច្នេះឯង

មកទៀតបានពួខ្ចរខ្ចាយ ទៅដល់ព្រះចៅប៉ះតូលេមី ហើយដើម្បីជាការតបស្នងសង គុណ ចំពោះអ្នកស្រុកកោះរ៉ូដស៏ ដែលធ្លាប់បានជួយព្រះអង្គ ក្នុងអំឡុងសង្គ្រាម បែងចែកទឹកដី ទើបទ្រង់បញ្ជាឱ្យឧត្តមនាវីទាំងឡាយរបស់ព្រះអង្គ ដឹកនាំហ្វូង នាវាចម្បាំងជាច្រើន ធ្វើដំណើរចេញពីអេហ្ស៊ីប ឆ្ពោះតម្រង់ទៅរកកោះរ៉ូដស៏ ក្នុង បំណងជួយរំដោះកោះនេះ ឱ្យរួចផុតពីក្រញ៉ាំនៃការឈ្លានពានរបស់សត្រូវ ។

ដោយមិនអាចទ្រាំទ្របាន ចំពោះការវាយសម្រុកចេញមក របស់អ្នកស្រុក កោះរ៉ូដស៏ បូករួមជាមួយនិងការវាយផ្ចប់ពីខាងក្រៅ របស់កងទ័ពមកពីអេហ្ស៊ីប ធ្វើឱ្យព្រះអង្គម្ចាស់ដេមេទ្រាស ត្រូវបញ្ជាឱ្យដកទ័ពថយជាបន្ទាន់ ដោយបន្សល់ទុក នៅត្រឹមការបរាជ័យយ៉ាងអាម៉ាស់ ជាមួយនិងសាកសពរាប់ម៉ឺននាក់នៃទាហាន របស់ព្រះអង្គ រួមជាមួយនិងអាវុធយុទ្ធោបករណ៍ជាច្រើន នៅលើសមរភូមិប្រយុទ្ធ (ហើយដែលក្រោយមកត្រូវបានគេស្លរំលាយ ដើម្បីយកទៅធ្វើជាទេវរូបខូឡូស៊ុស ដែលមានឈ្មោះល្បីល្បាញបំផុត នៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ) ។

ដើម្បីជាការអបអរទៅនឹងជ័យជំនះរបស់ខ្លួន ដែលមានទៅលើសត្រូវនៅ ក្នុងឆ្នាំ៣០៤មុនគ.ស អ្នកស្រុកកោះរ៉ូដស៏ទាំងអស់បានសម្រេចចិត្ត កសាងនូវមហា បដិមាខ្នាតយក្ស ដែលតំណាងឱ្យស៊ុរិយទេពហេលីអូស ដែលពួកគេតែងតែគោរព បូជា ។ អាវុធយុទ្ធភ័ណ្ឌគ្រប់ប្រភេទ ដែលបានបន្សល់ទុកដោយកងទ័ពសត្រូវ ត្រូវ បានគេយកទៅរំលាយ ដើម្បីហ៊ុមព័ទ្ធនៅផ្នែកខាងក្រៅនៃអង្គទេវរូប (ផ្នែកខាង ក្នុងកសាងអំពីថ្ម) រីឯប៉មដែលប្រើសម្រាប់ចាំយាមឃ្លាំមើលនគរ ក៏ត្រូវបានប្រើ ប្រាស់សម្រាប់ធ្វើជារន្ទា ក្នុងការស្ថាបនានេះផងដែរ ។

ទាក់ទិនទៅដល់ប្រវត្តិនៃការសាងសង់ នូវមហាទេវរូបនេះទៀតសោត លោកភ្លីនីបានសរសេរ រៀបរាប់ទុកយ៉ាងដូច្នេះថា " មហាទេវរូបខូឡូស៊ុសទាំងមូល ត្រូវប្រើរយៈពេលអស់១២ឆ្នាំ ក្នុងការស្ថាបនា ដោយចាប់ផ្ដើមនៅក្នុងឆ្នាំ២៩៤ មុនគ.ស និងបញ្ចប់ទៅវិញនៅក្នុងឆ្នាំ២៨២មុនគ.ស ។ សម្រាប់ស្ថានិក ដែលស្ថាបនានូវមហាទេវរូបនេះ គាត់គឺជាអ្នកស្រុកកោះរ៉ូដស៍ តាំងពីកំណើតឈ្មោះថាខារីស ។ ខារីសស្ថាបនាមហាទេវរូបនេះឡើង ដោយថ្មកែវពណ៌សតភ្ជាប់ដោយច្រវ៉ាក់នៅផ្នែកខាងក្នុង និងស្រោបដោយលោហធាតុពីខាងក្រៅ ។ ប្រអប់ជើងក៏ដូចជាកជើងរបស់ទេវរូប ត្រូវបានស្ថាបនាឡើងយ៉ាងរឹងមាំ ដើម្បីធានាដល់ការទ្រទ្រង់នូវទម្ងន់នៃតួទេវរូបទាំងមូល ។ ដើម្បីងាយស្រួលក្នុងការលើកយកនូវដុំថ្មធំៗ ក៏ដូចជាសម្ភារៈផ្សេងៗទៀត ឡើងទៅផ្នែកខាងលើនៃតួទេវរូប ខារីសបានចាក់ដីធ្វើជាទីទួលព័ទ្ធជុំវិញតួទេវរូប (ចាក់ឡើងខ្ពស់បន្តិចម្ដងៗទៅតាមកម្ពស់នៃតួទេវរូប ដែលបានស្ថាបនារួច) ហើយនិងកើបចេញវិញនៅពេល តួទេវរូបទាំងមូលត្រូវបានស្ថាបនារួចរាល់ "។ កំណត់ហេតុនោះបានបន្ថែមទៀតថា មហាទេវរូបខូឡូស៊ុសឈរបង្ហាញរាងយ៉ាងសង្ហារ នាមាត់ច្រកនៃកំពង់ផែនៅលើកោះរ៉ូដស៍ អស់រយៈពេលជាងកន្លះសតវត្សរ៍ ដោយជារៀងរាល់ព្រឹកតែងបានបញ្ចេញ នូវរស្មីចម្រុះពណ៌ដ៏ស្រស់ស្អាត ដែលកើតចេញពីការចាំងប៉ះនៃពន្លឺថ្ងៃ ជាមួយនឹងផ្ទៃលោហៈដែលស្រោបនៅផ្នែកខាងក្រៅនៃអង្គទេវរូប រហូតមកដល់ដំណាក់កាលចុងក្រោយ ដែលទេវរូបនេះត្រូវបានបំផ្លាញដោយ គ្រោះរញ្ជួយដីដ៏ខ្លាំងក្លាមួយនៅក្នុងឆ្នាំ ២២៦ មុនគ.ស ដែលបានធ្វើឱ្យវិនាសខូចខាតផងដែរ ទៅលើហេដ្ឋារចនាសម្ព័ន្ធជាច្រើន

នៅលើកោះរ៉ូដស៍ដ៏ស្រស់ស្អាត មួយនេះ។

ភ្លាមៗបន្ទាប់អំពីការបំផ្លាញនោះដែរ អ្នកស្រុកកោះរ៉ូដស៍ ក៏បានទទួលនូវព្រះរាជសំណើរពីព្រះចៅប៉ះតូលេមីទី៣ (ព្រះនត្តារបស់ព្រះចៅប៉ះតូលេមីដែលបានជួយសង្គ្រោះអ្នកស្រុកកោះរ៉ូដស៍ ឱ្យរួចផុតពីការឈ្លានពាន នៃកងទ័ពរបស់ព្រះចៅអង់ទីហ្គោស) របស់អេហ្ស៊ីប សុំឧបត្ថម្ភសម្រាប់ការជួសជុល និងស្ថាបនាជាថ្មីឡើងវិញ នូវមហាទេវរូបខូឡូស៊ុសនេះ។ ជាការគួរឱ្យសោកស្ដាយជាទីបំផុត ព្រោះថាព្រះរាជបំណងដ៏ល្អរបស់ស្ដេចអេហ្ស៊ីបអង្គនេះ ត្រូវបានបដិសេធយ៉ាងដាច់អហង្ការដោយអ្នកស្រុកកោះរ៉ូដស៍ដែលមានជំនឿថា អ្វីៗដែលបានកើតឡើងនេះ គឺសុទ្ធតែជាបំណងរបស់អាទិទេព ដែលប្រសិនបើពួកគេនៅតែជំនះកសាងទេវរូបនេះឡើងវិញ នោះពួកគេនឹងត្រូវទទួលរងនូវទណ្ឌកម្មផ្សេងៗដូចជា នឹងកើតមាននូវគ្រោះរញ្ជួយដី ជាថ្មីម្ដងទៀតជាដើម។




**មហាទេវរូបខូឡូស៊ុសដែលជើងទាំង២ ឈរគ្របពីលើច្រកចេញចូលកំពង់ផែ**

ទីបំផុតស្នាដៃនៃស្ថាបត្យកម្ម ដ៏ល្អឯកមួយនៅក្នុងលោក ដែលកសាងឡើង ដោយទឹកដៃដ៏ប៉ិនប្រសព្វរបស់ស្ថាបត្យករខារីស ត្រូវបានបញ្ចប់ជាស្ថាពរ ក្រោម ការសោកស្ដាយរបស់មនុស្សជំនាន់ក្រោយ ដែលមិនបានទស្សនាដោយផ្ទាល់ភ្នែក នូវសំណង់ ដែលត្រូវបានគេចាត់បញ្ចូល ជាវត្ថុដ៏អស្ចារ្យបំផុតមួយនៅក្នុងលោក ។

" ប៉ុន្តែទុកជាត្រូវបាក់ធ្លាក់ មកលើផែនដីក៏ដោយ វាក៏នៅតែអស្ចារ្យគួរឱ្យ កោតស្ញប់ស្ញែង ហើយបើនិយាយពីទំហំរបស់វាទៀតសោត គឺមានមនុស្សតិចនាក់ ណាស់ ដែលអាចយកដៃទាំងពីររបស់គេ ឱបឱ្យបានជុំជិត នូវម្រាមមេដៃរបស់អង្គ ទេវរូប " ទាំងនេះគឺជាពាក្យសម្ដីរបស់លោកភ្លីនី (Pliny) ប្រវត្តិវិទូសញ្ជាតិរ៉ូម៉ាំងដ៏ ល្បីល្បាញមួយរូបនាសម័យបុរាណ (មិត្តអ្នកអានសាកនឹកស្រមៃទៅមើល ថាតើតួ ទេវរូបទាំងមូលមានទំហំប៉ុណ្ណា) ។

ពិតមែនថាចាប់តាំងពីការកសាង រហូតឈានទៅដល់ការបំផ្លាញ ក្នុងរយៈ វេលា៥៦ឆ្នាំ វាជារយៈពេលមួយដ៏ខ្លី ប៉ុន្តែមហាទេវរូបខូឡូស៊ុសនៅតែអាចទាក់ ទាញបាននូវចំណាប់អារម្មណ៍ និងការកោតសរសើរ ពីសំណាក់អ្នកប្រាជ្ញផ្នែកបុរាណ វិទ្យា និងអ្នកនិពន្ធ ព្រមទាំងអ្នកទេសចរ ក៏ដូចជាស្ថាបត្យករជាច្រើននាយុគសម័យ នោះ ហើយដែលធ្វើឱ្យអ្នកទាំងនោះអត់ទ្រាំមិនបាន រហូតទាញស្លាបប៉ាកាចារឹកទុក ជាអច្ឆរិយវត្ថុមួយ ក្នុងចំណោមអច្ឆរិយវត្ថុទាំង៧នៃយុគបុរាណ មិនបញ្ឈប់ត្រឹម ប៉ុណ្ណោះឡើយ ឥទ្ធិពលរបស់វានៅបានបន្តមកដល់សព្វថ្ងៃ រហូតធ្វើឱ្យខ្ញុំត្រូវសម្រេច ចិត្តសរសេររៀបរៀងជាសៀវភៅនេះឡើង ដើម្បីយកមកអួតបង្ហាញពីភាព អស្ចារ្យនៃមហាស្ថាបត្យកម្មនេះ ឱ្យមិត្តអ្នកអានបានជ្រួតជ្រាបផងដែរ ។

អស់រយៈពេលជិតមួយសហសវត្សរ៍ ដែលសំណាកទេវរូបបាក់បែក ត្រូវស្ថិតនៅក្នុងសភាពទ្រុឌទ្រោម។ ក្នុងឆ្នាំ៦៥៤នៃគ.ស ពេលដែលកងទ័ពអារ៉ាប់លុកលុយកោះរ៉ូដស៍ ពួកគេមិនត្រឹមតែមិនបានជួសជុលផ្គុំឡើងវិញ នូវមហាទេវរូបនេះប៉ុណ្ណោះទេ ប៉ុន្តែគេបែជាលក់បំណែកផ្សេងៗនៃអង្គទេវរូប ទៅឱ្យពួកជនជាតិជីហ្វ ដែលធ្វើដំណើរមកពីប្រទេសស៊ីរៀទៅវិញ។

តាមកំណត់ហេតុដែលបន្សល់ទុករហូតមកដល់សព្វថ្ងៃ បានឱ្យដឹងថា បំណែកផ្សេងៗនៃអង្គទេវរូប ដែលត្រូវបានគេដឹកជញ្ជូនយក ទៅកាន់ប្រទេសស៊ីរៀ ត្រូវដាក់នៅលើខ្នងសត្វអូដ្ឋ ដែលមានចំនួនរហូតដល់ទៅ៩០០ ក្បាលឯណោះ។



**គំនូរទេវរូបខូឡូស៊ុសដែលគូរឡើងទៅតាមបទបរិយាយរបស់ប្រវត្តិវិទូភ្នំធី**

ទាក់ទងនឹងទីតាំងពិតប្រាកដ នៃមហាទេវរូបខូឡូស៊ុសនេះ មានមនុស្សជាច្រើនជឿថាមហាបដិមាយក្សនេះពេលស្ថាបនារួច គឺឈរនៅមុខកំពង់ផែ មេនដ្រាគី ដែលជាកំពង់ផែមួយ ក្នុងចំណោមកំពង់ផែជាច្រើននៅលើកោះរ៉ូដស៍ ក្នុងឥរិយាបថឈរកន្ធែកជើង គ្របពីលើច្រកចេញចូលនៃកំពង់ផែនោះ។ បើពិតយ៉ាងដូច្នោះមែន គេអាចសន្និដ្ឋានបានថា បំណែកនៃទេវរូបដែលបាក់ធ្លាក់ចុះមក ដោយគ្រោះរញ្ជួយដីប្រហែលជាបានបិទភ្ជិតនូវច្រកកំពង់ផែមេនដ្រាគី ដោយមិនអនុញ្ញាតឱ្យនាវាណាមួយ ឆ្លងកាត់ច្រកនេះបានឡើយ។

ដោយឡែកយោងទៅតាម ការសិក្សាស្រាវជ្រាវនាពេលបច្ចុប្បន្ន បានបង្ហាញឱ្យឃើញថា វាអាចនឹងត្រូវបានគេសាងសង់ នៅលើទីកន្លែងណាមួយ ក្នុងចំណោមទីកន្លែង២ផ្សេងគ្នា ដែលទីមួយគឺស្ថិតនៅឈូងសមុទ្រ ប៉ែកខាងកើតនៃច្រកមេនដ្រាគី និងទីពីរគឺប្រហែលជានៅកណ្ដាលកោះ។ ការសិក្សាខាងលើនេះបានបញ្ជាក់បន្ថែមទៀតថា មហាទេវរូបខូឡូស៊ុស គឺមិនធ្លាប់ត្រូវបានគេស្ថាបនាគ្របពីលើច្រកចេញចូលនៃកំពង់ផែមេនដ្រាគីនោះទេ។

ទុកណាជាវាបានបាត់បង់ទាំងស្រុងទៅហើយក្ដី ប៉ុន្តែប្រវត្តិនិងរឿងរ៉ាវមួយចំនួនរបស់វា ក្នុងនាមជាវត្ថុដ៏អស្ចារ្យមួយនៅក្នុងលោកនាសម័យបុរាណ នៅតែដក់ជាប់នៅក្នុងចិត្តរបស់មនុស្សជាតិ គ្មានថ្ងៃបំភ្លេចបាន។

សូមអញ្ជើញរកជាវនៅតាមបណ្ណាគារ
និងបញ្ជរលក់សៀវភៅគ្រប់ខេត្ត-ក្រុង

ISBN:99950-831-1-6